ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍

# បូកសរុបលទ្ធផលការងារ ១០ឆ្នាំ

# ២០០១-២០១១

# របាយការណ៍

# បូកសរុបលទ្ធផលការងារ ១០ឆ្នាំ

# ២០០១-២០១១

# អារម្ភកថា

ផ្តើមចេញពីលទ្ធផលនៃការបង្រួបបង្រួមជាតិ ដែលជាបំណងប្រាថ្នាតែមួយគត់របស់ប្រជាជាតិកម្ពុជាទូទាំងប្រទេស រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនូវគោលនយោបាយ ឈ្នះ ឈ្នះ និងយុទ្ធសាស្ត្រស្រួចស្រាល់ ដើម្បីជំរុញការកសាងប្រទេសឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយមានអភិបាលកិច្ចល្អ និងកាត់បន្ថយភាពក្រីក្រ។ កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលស្ថិតនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល មានទិសដៅធ្វើឲ្យសម្រេចនូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃកិច្ចប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋ។ កត្តានេះ គឺជាការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាល សម្រាប់ឈានឡើងប្រកបដោយក្តីសង្ឃឹមទៅអនាគតដ៏រុងរឿង និងសុខដុមរមនារបស់ប្រជាពលរដ្ឋ និងមាតុភូមិនៃយើង។

ក្នុងការធ្វើឲ្យសម្រេចនូវផែនការយុទ្ធសាស្ត្ររយៈពេលវែង រួមជាមួយកម្មវិធីកែទម្រង់លើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល អាជ្ញាធរសវនកម្មជាតិ ដែលជាស្ថាប័នសវនកម្មកំពូលពុំធ្លាប់មានពីមុនមកត្រូវបានបង្កើតឡើងនៅខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាល ព្រមទាំងមានការគាំទ្រពីរដ្ឋសភា និងព្រឹទ្ធសភា។ ការបង្កើតឲ្យមានអាជ្ញាធរសវនកម្មជាតិ នេះឡើង ដើម្បីជួយគាំទ្រដល់ដំណើរការអនុវត្តកម្មវិធីសកម្មភាពកែទម្រង់គ្រប់វិស័យដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការពិនិត្យ និងវាយតម្លៃដោយឯករាជ្យនូវកិច្ចប្រតិបត្តិការ និងការគ្រប់គ្រងធនធានរបស់រដ្ឋពីសំណាក់ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ហើយដែលអាជ្ញាធរត្រូវធ្វើ និងរាយការណ៍ជាប្រចាំជូនរដ្ឋសភា ព្រឹទ្ធសភា ទៅរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដើម្បីបានជ្រាប និងកែលម្អចំណុចអវិជ្ជមានទាំងឡាយ។

ចាប់ពីថ្ងៃបដិសន្ធិមកទល់ពេលនេះ អាជ្ញាធរសវនកម្មជាតិបានអនុវត្តការងារ មានអាយុកាលជប់ (១០)ឆ្នាំហើយ។ ជាមួយនេះ ក្រោមការខិតខំប្រឹងប្រែង រួមជាមួយឆន្ទៈដ៏មោះមុតរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទនៃអាជ្ញាធរសវនកម្មជាតិ និងមានការគាំទ្រទាំងស្មារតីក៏ដូចជាផ្នែកហិរញ្ញវត្ថុពីសភា ពីរាជរដ្ឋាភិបាល ព្រមជាមួយការគាំទ្រផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា និងដោយមានការសហការល្អពីបណ្តាក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មអាជ្ញាធរសវនកម្មជាតិសម្រេចបាននូវលទ្ធផលជាច្រើនគួរជាទីមោទនៈ និងភាពជឿជាក់។

ក្នុងនោះ ដើម្បីកំណត់ទិសដៅសកម្មភាពឲ្យបានម៉ឺងម៉ាត់ អាជ្ញាធរសវនកម្មជាតិបានបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង(២០០៧-២០១១) ដោយបានកំណត់នូវគោលបំណងសំខាន់ ៤យ៉ាង គឺការបង្កើតស្តង់ដារសវនកម្មរាជរដ្ឋាភិបាល (ស្តង់ដារសវនកម្មសាធារណៈ) សៀវភៅណែនាំ និងវិធីសាស្ត្រសវនកម្ម ការកសាងសមត្ថភាពស្ថាប័ន ការគាំទ្រផ្នែកបច្ចេកទេស

និងរដ្ឋបាល និងទំនាក់ទំនងជាមួយអតិថិជន។ ការអនុវត្តន៍ជាជំហានៗឲ្យបានសមស្របតាមផែនការយុទ្ធសាស្ត្រ ២០០៧-២០១១ បាននាំមកនូវការផ្លាស់ប្តូរមុខមាត់របស់អាជ្ញាធរសវនកម្មជាតិ ឲ្យក្លាយខ្លួនជាស្ថាប័នសវនកម្មកំពូលកាន់តែរឹងមាំ មានភាពឯករាជ្យ មានប្រសិទ្ធភាព និងមានការគាំទ្រកាន់តែប្រសើរពីសាធារណជន។

តាងនាមឲ្យអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងបណ្តាស្ថាប័នសវនកម្មកំពូលមួយចំនួន ដែលជានិច្ចកាលតែងជួយគាំទ្រអាជ្ញាធរសវនកម្មជាតិ ក្នុងដំណើរការអនុវត្តកិច្ចការរបស់ខ្លួនប្រកបដោយឯករាជ្យ ចាប់តាំងពីថ្ងៃកកើតរហូតដល់ថ្ងៃគម្រប់ ១០ឆ្នាំនេះ ទាំងក្នុងក្របខណ្ឌច្បាប់ ទាំងស្មារតី និងផ្នែកហិរញ្ញវត្ថុ ពិសេសសូមគោរព និងថ្លែងអំណរគុណចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលលោកបានផ្តល់អនុសាសន៍ល្អៗ ជាត្រីវិស័យសម្រាប់ការងារដឹកនាំស្ថាប័ន ក៏ដូចជាជួយគាំទ្រយ៉ាងពេញទំហឹងក្នុងការផ្តល់នូវគោលការណ៍ច្បាប់នានា រួមទាំងថវិកាជាប្រៀវត្ស និងសម្ភារបរិក្ខារទាន់ពេលវេលាសម្រាប់ដំណើរការស្ថាប័នថ្មីស្រឡាងនេះ ដែលជាការលើកទឹកចិត្តមន្ត្រីសវនករ ឲ្យបំពេញការងារដោយប្រសិទ្ធភាព។ ជាមួយនេះ ខ្ញុំសូមលើកសរសើរដល់មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិ ដែលតែងតែខិតខំពុះពារការលំបាកគ្រប់បែបយ៉ាងជារៀងរហូត ដើម្បីសម្រេចភារកិច្ច ហើយជឿជាក់ថា ទៅអនាគតការជួយជ្រោមជ្រែង និងការឧបត្ថម្ភគាំទ្រខាងលើ និងមានជាបន្តទៀត ដើម្បីឲ្យអាជ្ញាធរសវនកម្មជាតិសម្រេចបាននូវភាគព្វកិច្ចរបស់ខ្លួនប្រកបដោយផ្លែផ្កាសម្រាប់ភាពសុខដុមរមនា និងការរីកចំរើនរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិទាំងមូល។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១១

**អគ្គសវនករ**

# មាតិកា

ទំព័រ

**អារម្ភកថា**
**សេចក្តីផ្តើម** ........ ១
**ផ្នែកទី ១ : ស្ថានភាពទូទៅ**
**I- ប្រវត្តិសង្ខេប** ........ ២
**១- ប្រវត្តិកកើត** ........ ២
**២- ទីតាំង** ........ ២
**៣- គោលបំណង និងទស្សនវិស័យការងារ** ........ ២
៣.១- គោលបំណង ........ ២
៣.២- ប្រព័ន្ធសវនកម្ម ........ ២
៣.៣- ទស្សនវិស័យការងារ ........ ៣
៣.៤- ការរួមចំណែកជួយអង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ........ ៣
**II- ប្រព័ន្ធគ្រប់គ្រង** ........ ៤
**១- តួនាទី និងភារកិច្ច** ........ ៤
១.១- ការតែងតាំង និងតួនាទីរបស់ថ្នាក់ដឹកនាំ ........ ៤
១.២- សិទ្ធិអំណាច និងវិសាលភាព ........ ៤
**២- រចនាសម្ព័ន្ធគ្រប់គ្រង** ........ ៥
**ផ្នែកទី ២ : លទ្ធផលការងារ ១០ឆ្នាំ**
**I- លទ្ធផលការងារជួយគាំទ្រការងារសវនកម្ម** ........ ១០
**១- ការរៀបចំឯកសារគតិយុត្តិ** ........ ១០
១.១- ការរៀបចំលក្ខន្តិកៈដោយឡែកក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម ........ ១០
១.២- ការចេញសេចក្តីសម្រេច ........ ១២
១.៣- ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០០៧-២០១១) ........ ១២
១.៤- ការរៀបចំសៀវភៅណែនាំការគ្រប់គ្រងធនធានមនុស្ស ........ ១២
១.៥- ការរៀបចំសៀវភៅណែនាំការបណ្តុះបណ្តាល ........ ១៣
១.៦- ការរៀបចំគោលការណ៍ណែនាំរបៀបធ្វើរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈ ១៣
១.៧- ការរៀបចំស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា ........ ១៣
**២- ការចងក្រងឯកសារពាក់ព័ន្ធការងារសវនកម្ម** ........ ១៣
**៣- ការងារព័ត៌មានវិទ្យា** ........ ១៤
**៤- បណ្ណាល័យ** ........ ១៤
**៥- ការងារបណ្តុះបណ្តាល និងសិក្ខាសាលា** ........ ១៥
៥.១- វគ្គបណ្តុះបណ្តាល ........ ១៥
៥.១.១- វគ្គបណ្តុះបណ្តាលក្នុងប្រទេស ........ ១៥
៥.១.២- វគ្គបណ្តុះបណ្តាលក្រៅប្រទេស ........ ១៨

**៥.២- ការងារសិក្ខាសាលា** ........ ២១
៥.២.១- ការងារសិក្ខាសាលាថ្នាក់ជាតិ ........ ២១
៥.២.២- ការចូលរួមសិក្ខាសាលា និងទស្សកិច្ចសិក្សានៅក្រៅប្រទេស ........ ២៧
**៦- ការងារសហប្រតិបត្តិការ** ........ ២៧
**៦.១- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ** ........ ២៧
៦.១.១- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្បញ្ញត្តិ ........ ២៧
៦.១.២- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្រតិបត្តិ ........ ២៧
៦.១.៣- ការចូលរួមការងារសង្គម ........ ២៨
**៦.២- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសវនកម្មកំពូលអន្តរជាតិ** ........ ៣១
៦.២.១- ការចូលជាសមាជិកអង្គការអន្តរជាតិ ........ ៣១
៦.២.២- សកម្មភាពទំនាក់ទំនងជាលក្ខណៈអន្តរជាតិ ........ ៣២
៦.២.៣- ការចុះកិច្ចព្រមព្រៀងអនុស្សរណៈ នៃការយោគយល់គ្នា ........ ៣៥
៦.២.៤- គម្រោងគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ........ ៤០
**៧- ការងាររដ្ឋបាលទូទៅ** ........ ៤៥
៧.១. ការគ្រប់គ្រងមន្ត្រីរាជការ ........ ៤៥
៧.១.១- ស្ថិតិមន្ត្រីរាជការ ........ ៤៥
៧.១.២- កម្រិតវប្បធម៌ ........ ៤៥
៧.១.៣- ការលើកទឹកចិត្ត ........ ៤៦
៧.១.៤- ការពង្រឹងសមត្ថភាពស្ថាប័ន ........ ៥០
៧.២. ការគ្រប់គ្រងចំណូល ចំណាយថវិកា ........ ៥១
៧.៣. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ........ ៥១
**៨-ការត្រួតពិនិត្យឡើងវិញលើបច្ចេកទេសសវនកម្មមកលើអាជ្ញាធរសវនកម្មជាតិ**( Peer review ) ........ ៥២
**II- លទ្ធផលការងារសវនកម្ម** ........ ៥២
**១-សកម្មភាពចុះធ្វើសវនកម្ម** (២០០២-២០១១) ........ ៥២
**២-ការកែលម្អតាមអនុសាសន៍សវនកម្ម** ........ ៦៥
**ផ្នែកទី៣ : សេចក្តីសន្និដ្ឋាន** ........ ៦៨

# សេចក្តីផ្តើម

ក្នុងការអនុវត្តន៍ការងាររយៈពេល ១០ឆ្នាំ កន្លងមកនេះអាជ្ញាធរសវនកម្មជាតិ ចងក្រងជារបាយការណ៍ ដើម្បីបង្ហាញអំពីសមិទ្ធផលដែលជាការរួមចំណែកដល់កិច្ចដំណើរការអនុវត្តនូវគោលនយោបាយកែទម្រង់លើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល។

កម្រងរបាយការណ៍នេះ រួមមានបីផ្នែក គឺផ្នែកទី១ : ស្ថានភាពទូទៅ ផ្នែកទី២: លទ្ធផលការងារ ១០ឆ្នាំ និងផ្នែកទី៣: សេចក្តីសន្និដ្ឋាន។

ជាការពិត ក្នុងទិដ្ឋភាពច្បាប់ អាជ្ញាធរសវនកម្មជាតិបានចាប់ផ្តើមបើកទំព័រប្រវត្តិសាស្ត្ររបស់ខ្លួន ដោយបានរៀបចំនូវប្រព័ន្ធសកម្មភាពការងារសវនកម្មសាធារណៈ ដំបូងនាដើមឆ្នាំ ២០០២។ ក្នុងអំឡុងពេលពីរអាណត្តិ ១០ឆ្នាំដំបូងនេះ ក្រៅពីកិច្ចការគ្រប់គ្រង រដ្ឋបាលទូទៅ និងការងារបណ្តុះបណ្តាលធនធានមនុស្ស សមិទ្ធផលសម្រេចបានក្នុងក្របខណ្ឌជារបាយការណ៍លទ្ធផលសវនកម្ម បានបង្ហាញពីចំណុចអវិជ្ជមាន ដោយបានធ្វើឲ្យក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មនានាបន្តកែលម្អ និងពង្រឹងកិច្ចប្រតិបត្តិការតាមជំនាញរៀងៗខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ។ ក្រៅពីនេះ អាជ្ញាធរសវនកម្មជាតិបានកសាងនូវឯកសារគតិយុត្តិជាច្រើនទៀត ដោយមានការជួយគាំទ្រ និងកិច្ចសហការពីសំណាក់ដៃគូអភិវឌ្ឍន៍ទាំងក្នុងតំបន់ និងអន្តរជាតិ ប្រការសំខាន់គឺ អាជ្ញាធរសវនកម្មជាតិបង្កើតស្តង់ដារផ្ទាល់របស់ខ្លួនសមស្របតាមច្បាប់ជាធរមាន និងសមស្របតាមស្តង់ដារអន្តរជាតិ។

ការចងក្រងរបាយការណ៍បូកសរុបលទ្ធផលអនុវត្តការងាររបស់អាជ្ញាធរសវនកម្មជាតិក្នុងរយៈពេល ១០ឆ្នាំនេះ ជាឯកសារជំនួយស្មារតីដល់សវនករជំនាន់ក្រោយៗ ក៏ដូចជាក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មទាំងឡាយសិក្សាស្វែងយល់ និងដកស្រង់យកបទពិសោធន៍ចំណុចល្អៗនៃរបាយការណ៍នេះមកប្រើប្រាស់ទៅតាមកាលៈទេសៈ និងពេលវេលាចាំបាច់ក្នុងដំណើរវិវត្តន៍ជាក់ស្តែងក្នុងក្របខណ្ឌកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ។ ម្យ៉ាងទៀត របាយការណ៍នេះនឹងជួយសម្រួលដល់ទំនាក់ទំនងរវាងសវនករជាមួយបណ្តាអង្គភាពរងសវនកម្មឲ្យបង្កើននូវការសហការល្អ និងជិតស្និទ្ធជាបន្ថែមទៀត។ លើសពីនេះទៀត របាយការណ៍នេះ ជាធាតុផ្សំយ៉ាងសំខាន់ និងជាយុទ្ធសាស្ត្រ ដែលអាចជួយគាំទ្រដល់វិស័យសវនកម្មសាធារណៈនៅកម្ពុជាឲ្យពង្រឹងខ្លួនបានរឹងមាំ ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព។

# ផ្នែកទី ១
# ស្ថានភាពទូទៅ

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលដែលពុំធ្លាប់មានពីជំនាន់មុនៗ។ ការជំរុញឲ្យកើតជាស្ថាប័ននេះឡើង ដើម្បីរួមចំណែកក្នុងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចនូវគោលនយោបាយអភិបាលកិច្ចល្អ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព សមធម៌ និងកាត់បន្ថយភាពក្រីក្រ។ ឆន្ទៈជំរុញដ៏មោះមុតនេះ បានផ្តួចផ្តើមបង្កើតឡើងដោយការប្តេជ្ញាចិត្តដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅឆ្នាំ២០០១ ជាឆ្នាំទី៣ អាណត្តិទី២ នៃរាជរដ្ឋាភិបាល។

## I- ប្រវត្តិសង្ខេប

### ១- ប្រវត្តិកកើត

អាជ្ញាធរសវនកម្មជាតិ មានអក្សរកាត់ជាភាសាខ្មែរ "អ.ស.ជ" ជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ ហើយត្រូវបានបង្កើតដោយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។

### ២- ទីតាំង

បច្ចុប្បន្នអាជ្ញាធរសវនកម្មជាតិ មានទីតាំងស្ថិតនៅអគារលេខ១៦ ផ្លូវលេខ២៤០ (កែងផ្លូវប៉ាស្ទ័រ)សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

លេខទូរស័ព្ទ/ទូសារទំនាក់ទំនង: (៨៥៥-២៣) ២១៥ ៣២០, អ៊ីម៉ែល: naakh@naa.gov.kh គេហទំព័រ: www.naa.gov.kh។

### ៣- គោលបំណង និងទស្សនវិស័យការងារ

#### ៣.១- គោលបំណង

ការបង្កើតអាជ្ញាធរសវនកម្មជាតិ មានគោលបំណងដើម្បីបំពេញមុខងារជាស្ថាប័នសវនកម្មកំពូលដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការ និងទទួលខុសត្រូវក្នុងការអនុវត្តន៍មុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល រួមមានសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើកិច្ចប្រតិបត្តិការ និងសវនកម្មលើការអនុលោមតាមច្បាប់។ លទ្ធផលរបាយការណ៍សវនកម្មត្រូវផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងចម្លងជូនទៅរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដើម្បីបានជ្រាប ក្នុងគោលដៅជំរុញឲ្យមានការកែលម្អប្រព័ន្ធគ្រប់គ្រងទាំងឡាយ ដែលនៅមានចំណុចខ្វះខាត ឬមានភាពមិនប្រក្រតីក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

#### ៣.២-ទស្សនវិស័យការងារ

ក្នុងការធ្វើឲ្យសម្រេចបាននូវលទ្ធផលសវនកម្ម អាជ្ញាធរសវនកម្មជាតិបានបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលឆ្នាំ ២០០៧-២០១១ ដោយបានកំណត់នូវទស្សនវិស័យ៖

**ជួយរាជរដ្ឋាភិបាលគ្រប់គ្រងធនធានសាធារណៈដោយម៉ត់ចត់**
**និង**
**ជួយលើការទទួលខុសត្រូវផ្នែកសាធារណៈ តាមរយៈការធ្វើសវនកម្ម ប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត**

តាមរយៈលទ្ធផលសម្រេចបានក្នុងអំឡុងពេលពីរអាណត្តិ (១០ឆ្នាំ)កន្លងមកនេះនិងឈរលើស្មារតីយកចិត្តទុកដាក់អនុវត្តអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មមួយចំនួន មានការកែប្រែជាវិជ្ជមាននូវនីតិវិធីការងារ តាមជំនាញរៀងៗខ្លួន។

**៣.៣- ការរួមចំណែកជួយអង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ**

ក្នុងការធ្វើសវនកម្មលើប្រតិបត្តិការទូទាត់ថវិកាចំណូល-ចំណាយរបស់ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អាជ្ញាធរសវនកម្មជាតិធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា និងព្រឹទ្ធសភា។ ក្នុងដំណើការនេះ អាជ្ញាធរសវនកម្មជាតិត្រូវតែពង្រឹង និងធ្វើឲ្យប្រសើរឡើងនូវលទ្ធផលសវនកម្មដោយលើកយកអនុសាសន៍ល្អៗជូនរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីមានមូលដ្ឋានក្នុងការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងថវិកាទូទៅ និងជាពិសេសច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់បណ្តាឆ្នាំនីមួយៗ ដោយក្នុងនោះបានរួមចំណែកជួយជូនមតិដល់រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលលើការរៀបចំអនុម័តថវិកា និងចុងក្រោយបញ្ជាក់លើឯកសារនៃការទូទាត់ថវិការទូទៅរបស់រាជរដ្ឋាភិបាលទៀតផង ដូចមានគំនូសតាងខាងក្រោម៖



## II- ប្រព័ន្ធគ្រប់គ្រង

### ១- តួនាទី និងភារកិច្ច

#### ១.១- ការតែងតាំង និងតួនាទីរបស់ថ្នាក់ដឹកនាំ

ក្នុងក្របខណ្ឌជាស្ថាប័នសវនកម្មកំពូល អាជ្ញាធរសវនកម្មជាតិ ត្រូវបានការពារយ៉ាងពេញលេញដោយច្បាប់។ **អគ្គសវនករ** ក្នុងតួនាទីជាអ្នកដឹកនាំអាជ្ញាធរសវនកម្មជាតិមានសិទ្ធិក្នុងការទទួលខុសត្រូវលើការអនុវត្តន៍គោលនយោបាយ គោលដៅ និងគោលបំណងរបស់អាជ្ញាធរសវនកម្មជាតិ និងមានសិទ្ធិដើម្បីធ្វើសកម្មភាពរាល់កិច្ចការទាំងអស់ដែលមានចែងក្នុងច្បាប់នេះ ជាពិសេស **អគ្គសវនករ** ជាអ្នកតែងតាំង ផ្លាស់ប្តូរ ធ្វើកម្មវិបាក និងកំណត់បៀវត្ស អត្ថប្រយោជន៍ ប្រាក់កំរៃ ប្រាក់រង្វាន់ ដល់មន្ត្រីរាជការ និងបុគ្គលិករបស់អាជ្ញាធរសវនកម្មជាតិ។

ជាមួយនេះ អគ្គសវនករ និងអគ្គសវនកររង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល និងដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋភាតាមសំលេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ អគ្គសវនករ មានឋានៈ និងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និងអគ្គសវនកររងមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី។

អគ្គសវនករ និងអគ្គសវនកររង ត្រូវបានជ្រើសរើសសម្រាប់រយៈពេល ៥ឆ្នាំ ហើយអាចទទួលការតែងតាំងតែមួយដងទៀតប៉ុណ្ណោះ នៅពេលចប់អាណត្តិទី១ របស់ខ្លួន។

#### ១.២- សិទ្ធិអំណាច និងវិសាលភាព

តាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរសវនកម្មជាតិ មានបញ្ញត្តិដែលចែងលម្អិតក្នុងការពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការរបស់រាជរដ្ឋាភិបាល។ ខ្លឹមសារសង្ខេបដែលចែងដោយច្បាប់នេះ ចាប់ពីមាត្រា១៤ និងដល់១៧ បញ្ជាក់ថា អាជ្ញាធរសវនកម្មជាតិះ

- ជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យអំពីកិច្ចប្រតិបត្តិការ នៃការងារ
- មានសិទ្ធិអំណាចចេញសេចក្តីសម្រេច បទបញ្ជា សារាចរ និង ការណែនាំផ្សេងៗ
- មានលក្ខន្តិកៈដោយឡែក និង
- មានថវិកាដោយឡែកផ្តល់ដោយថវិកាជាតិ។

អាជ្ញាធរសវនកម្មជាតិ មានសិទ្ធអំណាចក្នុងការធ្វើសវនកម្មលើបណ្តាស្ថាប័នគ្រប់គ្រង រួមមានៈ បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុរដ្ឋចំរុះឯកជន សហគ្រាសសាធារណៈ គ្រឹស្ថានសាធារណៈ រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គភាពផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើដើមទុនផ្ទាល់ និងឥណទានរួមមាន ទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗ ទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជនផង។

ស្ថាប័នសវនកម្មកំពូលនេះ មានវិសាលភាពអំណាចទូលំទូលាយក្នុងការអនុវត្តន៍ការងារសវនកម្មលើវិស័យសាធារណៈ ដែលមានខ្លឹមសារសំអាងក្នុងក្របខណ្ឌនៃច្បាប់ចាប់ពីមាត្រា២២ ដល់មាត្រា២៩ ក្នុងជំពូក៥ ដែលចែងពីរបាយការណ៍នៃសវនកម្ម និងចាប់ពីមាត្រា៣០ ដល់មាត្រា៣៤ ក្នុងជំពូក៦ ដែលចែងពីសិទ្ធិអំណាចលើការប្រមូលផ្តុំព័ត៌មាន។

**២- រចនាសម្ព័ន្ធគ្រប់គ្រង**

ក្នុងក្របខណ្ឌច្បាប់ ប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ គឺផ្អែកលើតួនាទី និងភារកិច្ច ដែលមានចែងក្នុងច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ សជ/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ ទោះមានច្បាប់ស្តីពីការបង្កើតអាជ្ញាធរសវនកម្មជាតិជាស្ថាប័នសវនកម្មកំពូលហើយក្តី ក៏ការចាប់ផ្តើមអនុវត្តមិនអាចដំណើរការដោយងាយដែរ ដោយសារការចាប់ផ្តើមត្រូវធ្វើពីបាតដៃទទេ។

ក្នុងអំឡុងពេលរៀបចំពីដំបូង អាជ្ញាធរសវនកម្មជាតិ បានដាក់ចេញនូវសេចក្តីសម្រេចលេខ០០៣/០១ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រង នៃអាជ្ញាធរសវនកម្មជាតិ ដោយបង្កើតបាននូវរចនាសម្ព័ន្ធគ្រប់គ្រងមួយដែលដឹកនាំដោយ**អគ្គសវនករ** មួយរូប និងមានអគ្គសវនកររងពីររូប ដែលមានអគ្គលេខាធិការដ្ឋាន ព្រមទាំងនាយកដ្ឋានក្រោមឱវាទ។

ក្នុងរយៈពេល ១០ឆ្នាំ កន្លងមក អាជ្ញាធរសនវកម្មជាតិបានធ្វើការរៀបចំរចនាសម្ព័ន្ធរបស់ខ្លួន និងបានធ្វើការកែសម្រួលឲ្យសមស្របតាមទំហំការងារជាក់ស្តែង។

- រចនាសម្ព័ន្ធគ្រប់គ្រងឆ្នាំ ២០០១: មានអង្គភាពចំនួន៦ គិតរួមទាំងខុទ្ទកាល័យ និងមានការិយាល័យជំនាញចំនួន ១០
- រចនាសម្ព័ន្ធគ្រប់គ្រងឆ្នាំ ២០០៥ ដែលជារចនាសម្ព័ន្ធបច្ចុប្បន្នចែកចេញជា ៦ អង្គភាព រួមមាន:
  - ១- ខុទ្ទកាល័យ
  - ២- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
  - ៣- នាយកដ្ឋានបច្ចេកទេស
  - ៤- នាយកដ្ឋានសវនកម្មទី ១
  - ៥- នាយកដ្ឋានសវនកម្មទី ២
  - ៦- នាយកដ្ឋានសវនកម្មទី ៣។

ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងនេះផ្តោតសំខាន់ទៅលើការបង្កើតបន្ថែមនូវការិយាល័យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការងារ។ ចំពោះភារកិច្ចពុំមានការកែប្រែជាសំខាន់ទេ ដូចមានខ្លឹមសារសង្ខេបខាងក្រោម៖

- **អគ្គលេខាធិការដ្ឋាន:**

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការ ០១ (មួយ)រូប និងមានអគ្គលេខាធិការរងជាជំនួយការ(បច្ចុប្បន្នចំនួន០៣រូប)។ អគ្គលេខាធិការមានឋានៈស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈស្មើអនុរដ្ឋលេខាធិការ ដែលតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់អគ្គសវនករ។

អគ្គលេខាធិការដ្ឋានបច្ចុប្បន្នមាន ០៣ការិយាល័យ ជាជំនួយការ គឺការិយាល័យទី១ ការិយាល័យទី២និងការិយាល័យទី៣ ។

អគ្គលេខាធិការដ្ឋាន មានភារកិច្ចធ្វើជាសេនាធិការឲ្យអាជ្ញាធរសវនកម្មជាតិលើការងារ៖

- ធានានិរន្តរភាព នៃការងាររបស់អាជ្ញាធរសវនកម្មជាតិ
- គ្រប់គ្រង សម្របសម្រួល និងតាមដានកិច្ចការរបស់នាយកដ្ឋាននានា
- សម្របសម្រួលក្នុងការរៀបចំរបាយការណ៍សវនកម្ម

- លើកសំណើផ្សេងៗទាក់ទងដល់គោលនយោបាយ គោលដៅ គោលបំណង និងតាមដានការអនុវត្តន៍ភារកិច្ចទាំងនេះ
- លើកសំណើតែងតាំង ផ្លាស់ប្តូរភារកិច្ច អត្ថប្រយោជន៍ផ្សេងៗជូនអគ្គសនវករសម្រេច
- ទំនាក់ទំនង និងសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

- **នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

នាយកដ្ឋាននេះមាន ០៤ការិយាល័យ គឺការិយាល័យរដ្ឋបាល ការិយាល័យបុគ្គលិក ការិយាល័យហិរញ្ញវត្ថុ និងការិយាល័យផ្គត់ផ្គង់។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលលើការងាររដ្ឋបាល ចរាចរឯកសារ គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ពិធីការ សន្តិសុខ សណ្តាប់ធ្នាប់ ថវិកា ផ្គត់ផ្គង់សម្ភារៈ និងធ្វើរបាយការណ៍ស្តីពីសកម្មភាពផ្សេងៗ។

- **នាយកដ្ឋានបច្ចេកទេស**

នាយកដ្ឋាននេះមាន ០៦ការិយាល័យ គឺការិយាល័យនីតិកម្ម និងបណ្ណាល័យ ការិយាល័យស្រាវជ្រាវ និងបណ្តុះបណ្តាល ការិយាល័យព័ត៌មានវិទ្យា ការិយាល័យទំនាក់ទំនងអន្តរជាតិ ការិយាល័យកិច្ចការសាធារណៈ និងការិយាល័យទំនាក់ទំនងផ្ទៃក្នុង។

នាយកដ្ឋានបច្ចេកទេសមានភារកិច្ចសម្របសម្រួល រៀបចំ និងអនុវត្តភារកិច្ចលើការងារនីតិកម្ម វិវាទកម្ម បណ្ណាល័យ ព័ត៌មានវិទ្យា ស្រាវជ្រាវ បណ្តុះបណ្តាលមុខវិជ្ជាទាក់ទងការងារសវនកម្ម ទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

- **នាយកដ្ឋានសវនកម្មទី១**

នាយកដ្ឋាននេះមាន ០៤ការិយាល័យ គឺការិយាល័យសវនកម្មទី១.១ ការិយាល័យសវនកម្មទី១.២ ការិយាល័យសវនកម្មទី ១.៣ និងការិយាល័យសវនកម្មទី១.៤។

នាយកដ្ឋានសវនកម្មទី១ មានភារកិច្ចទទួលបន្ទុកចុះធ្វើសវនកម្មតាមបណ្តាក្រសួង-ស្ថាប័ន ។

- **នាយកដ្ឋានសវនកម្មទី២**

នាយកដ្ឋាននេះមាន ០៤ការិយាល័យ គឺការិយាល័យសវនកម្មទី២.១ ការិយាល័យសវនកម្មទី ២.២ ការិយាល័យសវនកម្មទី២.៣ និងការិយាល័យសវនកម្មទី២.៤។

នាយកដ្ឋានសវនកម្មទី២ មានភារកិច្ចទទួលបន្ទុកចុះធ្វើសវនកម្មតាមអាជ្ញាធរ ធនាគារជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ ស្ថាប័នហិរញ្ញវត្ថុរដ្ឋចំរុះឯកជន ព្រមទាំងបណ្តារដ្ឋបាលខេត្ត-ក្រុង និងរដ្ឋបាលមូលដ្ឋាន។

- **នាយកដ្ឋានសវនកម្មទី៣**

នាយកដ្ឋាននេះមាន ០៤ការិយាល័យ គឺការិយាល័យសវនកម្មទី៣.១ ការិយាល័យសវនកម្មទី៣.២ ការិយាល័យសវនកម្មទី៣.៣ និងការិយាល័យសវនកម្មទី៣.៤។

នាយកដ្ឋានសនវកម្មទី៣ មានភារកិច្ចទទួលបន្ទុកចុះធ្វើសវនកម្មលើភ្នាក់ងារអ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា កិច្ចសន្យាសម្បទាន កិច្ចសន្យាវិនិយោគ ការគ្រប់គ្រងគម្រោងឥណទាន អង្គការ សមាគម គណបក្សនយោបាយ និងសវនកម្មតាមសំណើពិសេស ។

ផ្អែកលើខ្លឹមសារសង្ខេបនៃរចនាសម្ព័ន្ធគ្រប់គ្រងក្រោយការកែសម្រួលក្នុងអាណត្តិទី២ នេះ អាជ្ញាធរសវនកម្មជាតិ សូមបង្ហាញជូននូវអង្គការលេខ នៃរចនាសម្ព័ន្ធគ្រប់គ្រងទាំងពីរអាណត្តិ រួមជាមួយរូបថតថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋាន ដូចតទៅ៖

## ថ្នាក់ដឹកនាំ នៃអាជ្ញាធរសវនកម្មជាតិ អាណត្តិទី១ (២០០១-២០០៦)



ឯកឧត្តម អ៊ុត ឈន អគ្គសវនករ



ឯកឧត្តម សេខ រ៉ុខ អគ្គសវនកររង



ឯកឧត្តម ស៊ិន ម៉ូ អគ្គសវនកររង

## រចនាសម្ព័ន្ធគ្រប់គ្រង ឆ្នាំ ២០០១



# ថ្នាក់ដឹកនាំ នៃអាជ្ញាធរសវនកម្មជាតិ អាណត្តិទី២ (២០០៦-២០១១)



ឯកឧត្តម **អ៊ុត ឈន** អគ្គសវនករ



ឯកឧត្តម **ឆាយ គឹម** អគ្គសវនកររង



ឯកឧត្តម **សេង រ៉ុង** អគ្គសវនកររង

## រចនាសម្ព័ន្ធគ្រប់គ្រង បច្ចុប្បន្ន



# ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងប្រធាននាយកដ្ឋានបច្ចុប្បន្ន



**ឯ.ឧ អ៊ុក សារាវុធ**
អគ្គលេខាធិការ



**ឯ.ឧ ប៉ា ហៀង**
អគ្គលេខាធិការរង



**ឯ.ឧ ឡុង អាទិច្ចបូរា**
អគ្គលេខាធិការរង



**ឯ.ឧ គឹម សុផល**
អគ្គលេខាធិការរង



**លោក យោក សាវ៉ាន់**
ប្រធាននាយកដ្ឋាន
រដ្ឋបាល និងហិរញ្ញវត្ថុ



**លោក ឆាយ នព្វគុណ**
ប្រធាននាយកដ្ឋាន
បច្ចេកទេស



**លោក ព្រហ្មវិចិត្រ សុភ័ណ្ឌ**
ប្រធាននាយកដ្ឋាន
សវនកម្មទី១



**លោក ឆែម សុជាតិ**
ប្រធាននាយកដ្ឋាន
សវនកម្មទី២



**លោក កែវ ជា**
ប្រធាននាយកដ្ឋាន
សវនកម្មទី៣

# អតីតថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងប្រធាននាយកដ្ឋាន



**ឯ.ឧ ច័ន្ទ តានី** អគ្គលេខាធិការ
(២០០១-២០០៦)



**ឯ.ឧ លុក ញ៉ិប** អគ្គលេខាធិការ
(២០០៦-២០១០)



**ឯ.ឧ អ៊ឹង ស៊ីឡុន** អគ្គលេខា
ធិការរង (២០០៧-២០១០)



**លោក ទូ ឈន**
ប្រធាននាយកដ្ឋាន
សវនកម្មទី២ (២០០៥-២០១០)

# ផ្នែកទី ២
# លទ្ធផលការងារ ១០ឆ្នាំ

## I- លទ្ធផលការងារជួយគាំទ្រដល់ការងារសវនកម្ម

ក្នុងរយៈពេល ១០ឆ្នាំនេះ ក្រៅពីការងារសវនកម្ម ដែលជាការងារមូលដ្ឋាន អាជ្ញាធរសវនកម្មជាតិបានខិតខំកសាង និងអនុវត្តនូវកិច្ចការផ្សេងៗ ដែលជួយគាំទ្រដល់ការងារជាមូលដ្ឋាន ដើម្បីពង្រឹង និងធានានិរន្តរភាព នៃការងារដល់ស្ថាប័ន។

### ១- ការងាររៀបចំឯកសារគតិយុត្តិ

រយៈពេល ១០ឆ្នាំកន្លងមកនេះ អាជ្ញាធរសវនកម្មជាតិបានរៀបចំឯកសារគតិយុត្តិបានមួយចំនួនស្របគ្នាជាមួយនឹងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង (៥ឆ្នាំ) ដើម្បីទុកជាមូលដ្ឋានសម្រាប់ដាក់ឲ្យប្រើប្រាស់ក្នុងការអនុវត្តន៍ការងារទាំងក្នុងបច្ចុប្បន្ននិងអនាគត។ ការរៀបចំឯកសារនេះ គឺឈរលើមូលដ្ឋានច្បាប់នានា និងស្តង់ដារសវនកម្មអន្តរជាតិ ដែលរួមមានខាងក្រោម ៖

#### ១.១- ការរៀបចំឯកសារលក្ខន្តិកៈដោយឡែកក្របខណ្ឌមន្ត្រីរាជការជាន់ខ្ពស់សវនកម្ម

ការរៀបចំលក្ខន្តិកៈដោយឡែកនេះ គឺជាការអនុវត្តន៍ឲ្យស្របតាមមាត្រា១៦ ក្នុងជំពូកទី៣ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា "**មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ មានលក្ខន្តិកៈដោយឡែក**" និងអនុក្រឹត្យលេខ០៩ អនក្រ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការដាក់ឲ្យអនុវត្តគំរូទូទៅ លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌ។ ការបង្កើតបាននូវលក្ខន្តិកៈដោយឡែកក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម ចាត់ទុកជាឯកសារគតិយុត្តសម្រាប់គ្រប់គ្រងមន្ត្រី នៃអាជ្ញាធរសវនកម្មជាតិ។

លក្ខន្តិកៈដោយឡែកក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិត្រូវបានដាក់ឲ្យអនុវត្តដោយព្រះរាជក្រឹត្យលេខនស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩។ ព្រះរាជក្រឹត្យនេះ មាន ៩ជំពូក និង២៧មាត្រា ហើយបានកំណត់ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មរួមមាន ៣ ឋានន្តរសក្តិ៖

- ឋានន្តរសក្តិទី១ : សវនករដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរសក្តិទី២ : សវនករដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរសក្តិទី៣ : សវនករ មាន ១៤ ថ្នាក់។

លក្ខន្តិកៈដោយឡែកនេះ បានកំណត់ថា៖

- មន្ត្រីក្នុងឋានន្តរសក្តិសវនករដើមខ្សែពិសេស មានឧបនិស្ស័យកាន់មុខតំណែងជាអគ្គលេខាធិការ អគ្គលេខាធិការរង ឬថ្នាក់ស្មើ ក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធ
- មន្ត្រីក្នុងឋានន្តរសក្តិសវនករដើមខ្សែ មានឧបនិស្ស័យកាន់មុខតំណែងជាប្រធាននាយកដ្ឋាន ឬថ្នាក់ស្មើ ក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធ
- មន្ត្រីក្នុងឋានន្តរសក្តិសវនករ មានឧបនិស្ស័យកាន់មុខតំណែងជាអនុប្រធាននាយកដ្ឋាន ឬថ្នាក់ស្មើ ក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធ ហើយមុខតំណែងនេះ ត្រូវសម្រេចដោយអគ្គសវនករ។





ឯកឧត្តម **អ៊ុត ឈន** និងថ្នាក់ដឹកនាំ អ.ស.ជ ចូលរួមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ឆ្លងសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែក ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩

**១.២- ការចេញសេចក្តីសម្រេច**

ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងសមស្របតាមច្បាប់ អាជ្ញាធរសវនកម្មជាតិ បានចេញសេចក្តីសម្រេចនានាដើម្បីធានានិរន្តរភាពការងារ និងជាឯកសារគតិយុត្តិសម្រាប់តម្រង់ទិសដែលគិតសរុបចាប់ពីឆ្នាំ ២០០១ ដល់ត្រឹមដំណាច់ឆ្នាំ២០១០ សម្រេចជាស្ថាពរបានប្រមាណចំនួន **៣៦៨លេខ**។

**១.៣- ការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០០៧-២០១១)**

ដោយមានការជួយជ្រោមជ្រែងពីសំណាក់ អង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) បច្ចុប្បន្ន(GIZ) អាជ្ញាធរសវនកម្មជាតិបានដាក់ចេញនូវផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ(២០០៧-២០១១) ផ្តោតសំខាន់លើការធ្វើឲ្យសម្រេចគោលបំណងសំខាន់ៗ ចំនួន៤ គឺ៖

- ការរៀបចំស្តង់ដារ សៀវភៅណែនាំ និងកម្មវិធីសវនកម្ម
- ការកសាងសមត្ថភាពស្ថាប័ន
- ការគាំទ្រផ្នែកបច្ចេកទេស និងរដ្ឋបាល
- ទំនាក់ទំនងអតិថិជន និងអ្នកពាក់ព័ន្ធ។

ផែនការយុទ្ធសាស្រ្តនេះ មាន១៧៧សកម្មភាព និងកម្មវិធីចំនួន៧៧ ដែលអាជ្ញាធរសវនកម្មជាតិ បានអនុវត្តដោយប្រុងប្រយ័ត្ន និងតាមលំដាប់លំដោយ ហើយទទួលបានជោគជ័យ និងលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ។

ទន្ទឹមនេះ ក្នុងឆ្នាំ ២០១១ អាជ្ញាធរសវនកម្មជាតិបាននឹងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ រយៈពេល៥ឆ្នាំ (២០១២-១០១៦) បន្តទៀត ក្នុងស្មារតីរំពឹងទុកថា នឹងទទួលបានជោគជ័យជាបន្តបន្ទាប់។

**១.៤- ការរៀបចំសៀវភៅណែនាំការគ្រប់គ្រងធនធានមនុស្ស**

ការរៀបចំសៀវភៅនេះ គឺជាការដកស្រង់ចេញពីឯកសារគតិយុត្តិនានា ដែលទាក់ទងដល់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ជាពិសេសស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងបានទទួលការឧបត្ថម្ភពីសំណាក់អង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់(GTZ)។ ចំពោះមុខ ការអនុវត្តន៍ការរៀបចំសៀវភៅនេះ សមស្របទៅតាមឯកសារគតិយុត្តិនានា ដែលទាក់ទងដល់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ដែលក្នុងអំឡុងពេលនេះ រាជរដ្ឋាភិបាល បាន និងកំពុងធ្វើបច្ចុប្បន្នភាពលើឯកសារចាស់ៗ ដើម្បីអនុវត្តបានសមស្របតាមនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាពខ្ពស់។

សៀវភៅនេះមាន ៨ផ្នែក រួមមាន៖

- ផ្នែកទី ១ : យុទ្ធសាស្រ្តនៃការគ្រប់គ្រងធនធានមនុស្ស
- ផ្នែកទី ២ : រចនាសម្ព័ន្ធ និងសិទ្ធិអំណាច នៃការគ្រប់គ្រងធនធានមនុស្ស
- ផ្នែកទី ៣ : គោលនយោបាយជ្រើសរើស
- ផ្នែកទី ៤ : គោលនយោបាយកម្មសិក្សា
- ផ្នែកទី ៥ : គោលនយោបាយអវត្តមាន

- ផ្នែកទី ៦ : គោលនយោបាយព្រឹត្តិបត្រពិន្ទុ
- ផ្នែកទី ៧ : គោលនយោបាយដំឡើងថ្នាក់
- ផ្នែកទី ៨ : គោលនយោបាយវិន័យ។

**១.៥- ការរៀបចំសៀវភៅណែនាំការបណ្តុះបណ្តាល**

សៀវភៅនេះ បានផ្តួចផ្តើមរៀបចំឡើងព្រមគ្នាជាមួយសៀវភៅណែនាំការគ្រប់គ្រងធនធានមនុស្ស ដោយមានការជួយជ្រោមជ្រែងពីសំណាក់អង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ ក្នុងគោលដៅផ្តល់នូវចំណេះដឹងថ្មីៗ និងមានប្រសិទ្ធភាពដល់មន្ត្រី អាជ្ញាធរសវនកម្មជាតិក្នុងការពង្រឹងគុណភាពសវនកម្មផង និងសម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការរៀបចំអភិវឌ្ឍន៍ដល់ស្ថាប័ន។ សៀវភៅនេះ ផ្តោតសំខាន់លើផែនការ និងកម្មវិធីបណ្តុះបណ្តាលទាំងនៅក្នុង និងក្រៅប្រទេស មាន ៣ផ្នែក រួមមានគឺៈ

- ផ្នែកទី១ : យុទ្ធសាស្ត្របណ្តុះបណ្តាល
- ផ្នែកទី២ : គោលនយោបាយបណ្តុះបណ្តាល
- ផ្នែកទី៣ : កម្មវិធីបណ្តុះបណ្តាល។

**១.៦- ការរៀបចំគោលការណ៍ណែនាំអំពីរបៀបធ្វើរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈ**

ការរៀបចំគោលការណ៍ណែនាំនេះ អនុលោមតាមមាត្រា២៩ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា «**របាយការណ៍ដែលធ្វើដោយអគ្គសវនករត្រូវបានចាត់ទុកជាឯកសារសាធារណៈ**» និងមាត្រា៣៧ ដល់មាត្រា៣៩ ដែលចែងពី«**ប្រការគួរមិនផ្សព្វផ្សាយ**» ព្រមទាំងសមស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ។ គោលការណ៍ណែនាំបានបង្ហាញពីរបៀបធ្វើការផ្សព្វផ្សាយជាសាធារណៈដោយបញ្ចូលនូវចំណុចខ្វះខាតមួយចំនួនក្នុងអំឡុងពេលចុះធ្វើសវនកម្មលើការគ្រប់គ្រងរបស់បណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលខេត្ត-ក្រុង និងរដ្ឋបាលមូលដ្ឋាន។

ការរៀបចំគោលការណ៍ណែនាំ មានគោលបំណងធ្វើឲ្យរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈ ទទួលបានប្រសិទ្ធភាព និងទាន់ពេលវេលា។

**១.៧- ការរៀបចំស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា**

ក្នុងការអនុវត្តន៍ការងារសវនកម្មសាធារណៈនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិពឹងផ្អែកលើស្តង់ដារ INTOSAI ដែលជាស្តង់ដារសវនកម្មសាធារណៈ សម្រាប់បណ្តាប្រទេសលើពិភពលោក។ នៅឆ្នាំ២០១១នេះ យើងបានរៀបចំចងក្រងជាស្តង់ដារសវនកម្មសាធារណៈឡើង ដើម្បីឲ្យការធ្វើសវនកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់ ហើយឯកសារនេះចាត់ទុកជាមូលដ្ឋានគ្រឹះសម្រាប់ជំនាញសវនកម្មសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។

**២- ការចងក្រងឯកសារពាក់ព័ន្ធការងារសវនកម្ម**

ក្នុងរយៈពេល ១០ឆ្នាំនេះ ក្រៅពីការងារសវនកម្ម អាជ្ញាធរសវនកម្មជាតិបានរៀបចំ និងចងក្រងជាឯកសារស្រាវជ្រាវពាក់ព័ន្ធជំនាញសវនកម្មមួយចំនួន រួមមានៈ

- សៀវភៅស្តីពីក្រមសីលធម៌ និងស្តង់ដារសវនកម្ម របស់អង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល (INTOSAI)
- សៀវភៅទ្រឹស្តីសវនកម្មលើវិស័យសាធារណៈ
- សៀវភៅសវនកម្មលើកិច្ចប្រតិបត្តិការ
- The  Role of Audit in Promoting Governmental Accountability.
- Texts on Corruption Prevention.
- Value and Benefits of Government Audit in a Globalized Environment.
- Professional Standards Committee/Sub Committee on SAI Independence.
- គោលការណ៍ណែនាំសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ
- សន្ធានុក្រមអង់គ្លេស-ខ្មែរ ស្តីពីប្រជុំស័ព្ទគណនេយ្យ និងសវនកម្ម
- សៀវភៅណែនាំស្តីពីការធានាគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
- សៀវភៅណែនាំ ស្តីពីការធ្វើសវនកម្មលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងបណ្តាឆ្នាំនីមួយៗ។

ជាមួយនេះ អាជ្ញាធរសវនកម្មជាតិ កំពុងបន្តរៀបចំគោលការណ៍ណែនាំការធ្វើសវនកម្មសំខាន់ៗ មួយចំនួនទៀតរួមមាន៖

- គោលការណ៍ណែនាំការធ្វើសវនកម្មលើគយ និងរដ្ឋាករ និងពន្ធដារ
- គោលការណ៍ណែនាំការធ្វើសវនកម្មលើកិច្ចលទ្ធកម្មសាធារណៈ
- គោលការណ៍ណែនាំការធ្វើសវនកម្មលើធនាគារជាតិ ។ល។

**៣- ការងារព័ត៌មានវិទ្យា**

ដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍន៍ អាជ្ញាធរសនវកម្មជាតិបានយកចិត្តទុកដាក់រៀបចំលើផ្នែកព័ត៌មានវិទ្យា ដែលជាការងារយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍន៍ការងារសវនកម្ម ក្នុងនោះរួមមាន ៖

- បង្កើត និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អាជ្ញាធរសវនកម្មជាតិ
- បង្កើត និងបំពាក់កុំព្យូទ័រ បន្ទប់សិក្សាព័ត៌មានវិទ្យា
- បង្កើត និងថែទាំបណ្តាញណេតវើក និងកុំព្យូទ័រមេ
- អនុវត្តកម្មវិធីTeamMate ក្នុងការងារសវនកម្ម។

**៤- បណ្ណាល័យ**

អាជ្ញាធរសវនកម្មជាតិ បានបង្កើតបណ្ណាល័យតាំងពីឆ្នាំ ២០០៣ ដោយបានស្រាវជ្រាវ និងថែរក្សាសៀវភៅ និងឯកសារសំខាន់ៗជាច្រើន ដើម្បីទុកឲ្យសវនករ និងមន្ត្រីជំនាញដទៃទៀតចូលសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីសមិទ្ធផលសវនកម្មតាមបណ្តាឆ្នាំនីមួយៗ

## ៥- ការងារបណ្តុះបណ្តាល និងសិក្ខាសាលា

### ៥.១- ការងារបណ្តុះបណ្តាល

ក្នុងរយៈពេល ១០ឆ្នាំនេះ អាជ្ញាធរសវនកម្មជាតិបានរៀបចំបណ្តុះបណ្តាលនៅក្នុងប្រទេស និងបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេសបានជាច្រើនវគ្គ។

#### ៥.១.១- វគ្គបណ្តុះបណ្តាលក្នុងប្រទេស

ជារៀងរាល់ឆ្នាំ អាជ្ញាធរសវនកម្មជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីសវនកម្ម និងមន្ត្រីសវនកម្មផ្ទៃក្នុងពីបណ្តាក្រសួង ស្ថាប័ននានាជាច្រើន ដើម្បីបំពាក់បំប៉នជំនាញសវនកម្ម និងផ្តល់ការយល់ដឹងជាទូទៅស្តីពីសវនកម្ម ស្តង់ដារសវនកម្ម និងនីតិវិធីសវនកម្មលើក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មនានា ដែលចាប់ពីឆ្នាំ ២០០២ បានចំនួន ៨១វគ្គ រួមមាន៖

| ល.រ | បរិយាយ | ចំនួនមន្ត្រីចូលរួម |
|---|---|---|
| | **ឆ្នាំ ២០០២** (ចំនួន ០៦វគ្គ) | |
| ១ | ការយល់ដឹងជាទូទៅស្តីពីសវនកម្ម | ៥២ |
| ២ | ស្តង់ដារសវនកម្ម INTOSAI | ៥៥ |
| ៣ | នីតិវិធីសវនកម្មលើក្រសួង ស្ថាប័ន | ៤៨ |
| ៤ | ថវិការដ្ឋ | ៥០ |
| ៥ | បំពាក់បំប៉នជំនាញថវិកា | ៥៧ |
| ៦ | បំពាក់បំប៉នជំនាញសវនកម្ម | ៥៧ |
| | **ឆ្នាំ ២០០៣** (ចំនួន ០៦វគ្គ) | |
| ១ | បច្ចេកវិទ្យាព័ត៌មានកុំព្យូទ័រ | ៣៥ |
| ២ | ជំនាញសវនកម្ម | ៥០ |
| ៣ | ជំនាញសវនកម្ម | ៤៦ |
| ៤ | គណនេយ្យសាធារណៈ និងបទពិសោធន៍ការងារសវនកម្ម | ៥៥ |
| ៥ | ប្រតិបត្តិការឃុំ-សង្កាត់ | ៣៥ |
| ៦ | គ្រប់គ្រងសវនកម្ម | ២៨ |
| | **ឆ្នាំ ២០០៤** (ចំនួន ០៣វគ្គ) | |
| ១ | ការងារឃុំ-សង្កាត់ | ៣៥ |
| ២ | ការងារសវនកម្ម | ៥១ |
| ៣ | ការងារពិនិត្យឡើងវិញ (Review) | ១៨ |
| | **ឆ្នាំ ២០០៥** (ចំនួន ០៥វគ្គ) | |
| ១ | សវនកម្មលើគម្រោង | ១២ |
| ២ | សវនកម្មធនាគារ | ០៨ |
| ៣ | សវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | ១៥ |

| | | |
|---|---|---|
| ៤ | ប្លង់គណនេយ្យទូទៅ | ៦៥ |
| ៥ | ក្រមសីលធម៌របស់អាជ្ញាធរសវនកម្មជាតិ | ១២៥ |
| | **ឆ្នាំ ២០០៦** (ចំនួន ១៤វគ្គ) | |
| ១ | សវនកម្មលើបរិយាកាសប្រព័ន្ធកុំព្យូទ័រ | ៩៥ នាក់ |
| ២ | ប្លង់គណនេយ្យទូទៅ រតនាគារ ឃុំ សង្កាត់ | ៩៦ នាក់ |
| ៣ | ការរៀបចំថវិកា | ៣៥ នាក់ |
| ៤ | កិច្ចប្រតិបត្តិការថវិកា (តារាង TOFE) | ៣៥ នាក់ |
| ៥ | ការយល់ដឹងទៅលើទស្សនៈច្បាប់របស់រាជរដ្ឋាភិបាល និងច្បាប់សវនកម្ម | ៧០ នាក់ |
| ៦ | រចនាសម្ព័ន្ធគ្រប់គ្រងនៃអាជ្ញាធរសវនកម្មជាតិ | ៧០ នាក់ |
| ៧ | ទ្រឹស្តីសវនកម្ម | ៧០ នាក់ |
| ៨ | សវនកម្មលើផ្នែកសាធារណៈ | ៧០ នាក់ |
| ៩ | ចំណេះដឹងលើការប្រើប្រាស់ប្រព័ន្ធ Computer Network | ៧០ នាក់ |
| ១០ | សវនកម្មផ្ទៃក្រៅសវនកម្មផ្ទៃក្នុង និង Lima Declaration | ៧០ នាក់ |
| ១១ | ប្រតិបត្តិការឃុំ-សង្កាត់ | ៧៧ នាក់ |
| ១២ | ខូបថវិកា | ១០៤ នាក់ |
| ១៣ | សវនកម្មលើស្ថាប័នហិរញ្ញវត្ថុសាធារណៈ | ១៥ នាក់ |
| ១៤ | បច្ចេកទេសគ្រប់គ្រងក្រុមការងារសវនកម្ម | ៨៥ នាក់ |
| | **ឆ្នាំ ២០០៧** (ចំនួន ១១វគ្គ) | |
| ១ | កម្មវិធីវិភាគទិន្នន័យសវនកម្មតាមកម្មវិធី ACL (Analysis Comment Language) | ៤២ នាក់ |
| ២ | ក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុង | ៩៩ នាក់ |
| ៣ | ការអនុវត្តន៍បទបញ្ជាស្តីពីការប្រើប្រាស់ព័ត៌មានវិទ្យា និងការយល់ដឹងទូទៅស្តីពីការប្រើប្រាស់បណ្តាញកុំព្យូទ័រ ក្នុង អ.ស.ជ | ៦១ នាក់ |
| ៤ | ការគ្រប់គ្រងថវិការដ្ឋ | ៦០ នាក់ |
| ៥ | បច្ចេកទេសគ្រប់គ្រងការងារសវនកម្ម | ៨៥ នាក់ |
| ៦ | សវនកម្មសាធារណៈរបស់ប្រទេសអាល្លឺម៉ង់ | ៧៣ នាក់ |
| ៧ | បច្ចេកទេសសម្ភាសន៍របស់សវនករ | ២៦ នាក់ |
| ៨ | ជំនាញភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង | ១៥ នាក់ |
| ៩ | សវនកម្មលើកិច្ចប្រតិបត្តិការ | ២៩ នាក់ |
| ១០ | សវនកម្មលើសំណង់ និង ការគ្រប់គ្រង | ៣២ នាក់ |
| ១១ | សវនកម្មលើពន្ធដារ | ៤៤ នាក់ |

| | | |
|---|---|---|
| | **ឆ្នាំ ២០០៨** (ចំនួន ១៩វគ្គ) | |
| ១ | ការយល់ដឹងអំពីថវិកាជាតិ | ៦៣ នាក់ |
| ២ | គណនេយ្យទូទៅ | ៦០ នាក់ |
| ៣ | ការគ្រប់គ្រងថវិកាខេត្ត-ក្រុង | ៧១ នាក់ |
| ៤ | សវនកម្មលើកិច្ចប្រតិបត្តិការ | ៥៨ នាក់ |
| ៥ | ការយល់ដឹងអំពីប្រព័ន្ធព័ត៌មានវិទ្យា | ៤៥ នាក់ |
| ៦ | ភាពជាអ្នកដឹកនាំសវនកម្ម | ៥០ នាក់ |
| ៧ | ការគ្រប់គ្រងកិច្ចសន្យា | ២៥ នាក់ |
| ៨ | ប្រព័ន្ធគ្រប់គ្រងគុណភាពសវនកម្ម | ៤៨ នាក់ |
| ៩ | ស្តង់ដារគណនេយ្យកម្ពុជា | ៨៥ នាក់ |
| ១០ | កិច្ចការបរទេស និងការធានាគុណភាពសវនកម្ម | ៨២ នាក់ |
| ១១ | Peachtree Accounting | ៣៦ នាក់ |
| ១២ | ការណែនាំអំពីកិច្ចសវនកម្មលើគំរោងប្រាក់កម្ចី | ២៦ នាក់ |
| ១៣ | Microsoft | ៨ នាក់ |
| ១៤ | ការកសាង និងគ្រប់គ្រងក្រុម | ៣០ នាក់ |
| ១៥ | ការកសាងសមត្ថភាពក្រុម | ៥៥ នាក់ |
| ១៦ | សវនកម្មលើការទូទាត់ថវិកា | ២៣ នាក់ |
| ១៧ | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៥៥ នាក់ |
| ១៨ | ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ | ២៤ នាក់ |
| ១៩ | កម្មវិធី TeamMate (User) | ១៩ នាក់ |
| | **ឆ្នាំ ២០០៩** (ចំនួន ០៨វគ្គ) | |
| ១ | ការគ្រប់គ្រងពេលវេលា និង ជំនាញសម្ភាសន៍ | ៥០ នាក់ |
| ២ | ការធ្វើសវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុង | ៥០ នាក់ |
| ៣ | មូលដ្ឋានគ្រឹះនៃការត្រួតពិនិត្យផ្ទៃក្នុង និង សវនកម្ម | ០៦ នាក់ |
| ៤ | តាមដាន និងវាយតម្លៃវគ្គសិក្សាផ្នែកសវនកម្មសាធារណៈ | ១៥ នាក់ |
| ៥ | សវនកម្មលើធនាគារជាតិ | ០៦ នាក់ |
| ៦ | Microsoft Office Share Point Server 2007 | ១៣ នាក់ |
| ៧ | ការអភិវឌ្ឍន៍ធនធានមនុស្សនៅ អ.ស.ជ | ២៧ នាក់ |
| ៨ | គោលការណ៍គ្រឹះសម្រាប់ធ្វើសវនកម្មគម្រោងជំនួយក្រៅប្រទេស | ២៥ នាក់ |
| | **ឆ្នាំ ២០១០** (ចំនួន ០៩វគ្គ) | |
| ១ | ការប្រើកម្មវិធី TeamMate សម្រាប់ធ្វើសវនកម្មលើសហគ្រាសសាធារណៈ | ៣៦ នាក់ |

| | | |
|---|---|---|
| ២ | ការគ្រប់គ្រងកិច្ចសន្យា | ៣៦ នាក់ |
| ៣ | ការយល់ដឹងពីការក្លែងបន្លំ និងអំពើពុករលួយ | ៩៥ នាក់ |
| ៤ | ផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងច្បាប់ស្តីពីលក្ខន្តិកៈ ដោយឡែកក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃ អ.ស.ជ | ១៨១ នាក់ |
| ៥ | ស្តង់ដារគណនេយ្យកម្ពុជា | ៧៦ នាក់ |
| ៦ | គោលការណ៍គ្រឹះសម្រាប់ធ្វើសវនកម្មលើគម្រោង | ៣៨ នាក់ |
| ៧ | មូលដ្ឋានច្បាប់ | ២៦ នាក់ |
| ៨ | ស្ថិតិ និងកម្មវិធី SPSS | ២៦ នាក់ |
| ៩ | ការត្រួតពិនិត្យ និងការវាយតម្លៃ | ១៨ នាក់ |

### ៥.១.២- វគ្គបណ្តុះបណ្តាលក្រៅប្រទេស

ជារៀងរាល់ឆ្នាំ អាជ្ញាធរសវនកម្មជាតិ បានរៀបចំចាត់បញ្ជូនមន្ត្រីសវនកម្មជាច្រើនឲ្យទៅចូលរួមវគ្គបណ្តុះបណ្តាល និងធ្វើទស្សនកិច្ចសិក្សានៅក្រៅប្រទេស ដូចជា៖

| ល.រ | ចំនួន ០៣ វគ្គ | មន្ត្រីចូលរួម | ទីកន្លែង |
|---|---|---|---|
| | **ឆ្នាំ ២០០៣** (ចំនួន ០៣វគ្គ) | | |
| ១ | ការប្រឆាំងអំពើពុករលួយ | ០១ នាក់ | ម៉ាឡេស៊ី |
| ២ | ទស្សនកិច្ចសិក្សា | ០៥ នាក់ | ម៉ាឡេស៊ី |
| ៣ | GAO Fellowship Program | ០២ នាក់ | អាមេរិក |
| | **ឆ្នាំ ២០០៤** (ចំនួន ០៤វគ្គ) | | |
| ១ | 64th ITP on Auditing in IT Environment | ០២ នាក់ | ឥណ្ឌា |
| ២ | សវនកម្មផ្ទៃក្រៅ | ០២ នាក់ | ថៃ |
| ៣ | សិក្ខាសាលាស្តីពីហិរញ្ញវត្ថុសាធារណៈ | ០១ នាក់ | អូស្ត្រាលី |
| ៤ | Audit of Social Sector | ០២ នាក់ | ឥណ្ឌា |
| | **ឆ្នាំ ២០០៥** (ចំនួន ០៤វគ្គ) | | |
| ១ | Audit of IT Environment | ០២ នាក់ | ឥណ្ឌា |
| ២ | សវនកម្មលើសហគ្រាសសាធារណៈ | ០២ នាក់ | ឥណ្ឌា |
| ៣ | In-Company-Training (Audit) | ០២ នាក់ | អាល្លឺម៉ង់ |
| ៤ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១ នាក់ | ឥណ្ឌា |
| | **ឆ្នាំ ២០០៦** (ចំនួន ០៨វគ្គ) | | |
| ១ | Regional Workshop on Public Procurement | ០១ នាក់ | ឥណ្ឌូនេស៊ី |
| ២ | សិក្ខាសាលាស្តីពីការធ្វើសវនកម្មលើនីតិវិធីលទ្ធកម្មសាធារណៈ | ០១ នាក់ | ឥណ្ឌូនេស៊ី |

| | | | |
|---|---|---|---|
| ៣ | Audit of Public Enterprises and Disinvestment Issue | ០២ នាក់ | ឥណ្ឌា |
| ៤ | 23rd Session on International Standards of Accounting | ០១ នាក់ | ស្វីស |
| ៥ | Anti-Corruption 2006-2007 | ០១ នាក់ | ហ្វីលីពីន |
| ៦ | International Trainning Program for Government Auditors | ០១ នាក់ | កូរ៉េ |
| ៧ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០២ នាក់ | ឥណ្ឌា |
| ៨ | Auditing on Information Technology Environment | ០២ នាក់ | ឥណ្ឌា |
| | **ឆ្នាំ ២០០៧** (ចំនួន ១៧ វគ្គ) | | |
| ១ | Internship on Auditing | ០២ នាក់ | អាល្លឺម៉ង់ |
| ២ | សវនកម្មលើបរិស្ថាន | ០១ នាក់ | ឥណ្ឌា |
| ៣ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០៤ នាក់ | ថៃ |
| ៤ | Managing Audit Result | ០១ នាក់ | ឥណ្ឌា |
| ៥ | Audit on Energy Sector | ០១ នាក់ | ឥណ្ឌា |
| ៦ | Risk Management in Banking | ០១ នាក់ | ស៊ុយអ៊ែត |
| ៧ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១ នាក់ | ម៉ាឡេស៊ី |
| ៨ | Financial Audit and Fraud Awareness Workshop | ០៤ នាក់ | ម៉ាឡេស៊ី |
| ៩ | សវនកម្មលើកិច្ចប្រតិបត្តិការ | ១៥ នាក់ | ម៉ាឡេស៊ី |
| ១០ | System Based Audit | ០១ នាក់ | កូរ៉េ |
| ១១ | Audit Training Course | ០១ នាក់ | ចិន |
| ១២ | International Trainign Program for Government Auditors | ០២ នាក់ | កូរ៉េ |
| ១៣ | The 23 ISAR Meeting at GENEVA | ០១ នាក់ | ស្វីស |
| ១៤ | Anti-Corruption | ០១ នាក់ | ឥណ្ឌូនេស៊ី |
| ១៥ | IT Audit | ០១ នាក់ | ម៉ាឡេស៊ី |
| ១៦ | Financial Audit in a Information technology environment | ០១ នាក់ | ប៉ាគីស្ថាន |
| ១៧ | Environment audit | ០២ នាក់ | ឥណ្ឌា |
| | **ឆ្នាំ ២០០៨** (ចំនួន ០៦ វគ្គ) | | |
| ១ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១ នាក់ | ម៉ាឡេស៊ី |
| ២ | Quality Assurance on Financial Audit | ០៣ នាក់ | ម៉ុងហ្គោលី |

| | | | |
|---|---|---|---|
| ៣ | Public Audit Management | ០១ នាក់ | កូរ៉េ |
| ៤ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១ នាក់ | ឥណ្ឌា |
| ៥ | Certificate in Spoken English & IT Skills | ០១ នាក់ | ឥណ្ឌា |
| ៦ | Financial Certificate Audit | ០១ នាក់ | ឥណ្ឌា |
| | **ឆ្នាំ ២០០៩** (ចំនួន ១៦ វគ្គ) | | |
| ១ | Certificate Course in Advanced Software Technology | ០១ នាក់ | ឥណ្ឌា |
| ២ | សវនកម្មលើបរិស្ថាន | ០១ នាក់ | ឥណ្ឌា |
| ៣ | Audit of Social Sector Programs | ០១ នាក់ | ឥណ្ឌា |
| ៤ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១ នាក់ | ម៉ាឡេស៊ី |
| ៥ | ការធានាគុណភាពសវនកម្ម | ០៣ នាក់ | ឥណ្ឌូនេស៊ី |
| ៦ | Risk Management in Banking | ០២ នាក់ | ស៊ុតអ៊ែត |
| ៧ | Policy Public Management | ០៣ នាក់ | ជប៉ុន |
| ៨ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១ នាក់ | ម៉ាឡេស៊ី |
| ៩ | Audit of Public Sector Enterprise | ០២ នាក់ | ឥណ្ឌា |
| ១០ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០២ នាក់ | ឥណ្ឌា |
| ១១ | Audit of Receipt | ០២ នាក់ | ឥណ្ឌា |
| ១២ | Financial and Regulatory Audit | ០២ នាក់ | ឥណ្ឌា |
| ១៣ | Auditing in IT Environment | ០២ នាក់ | ឥណ្ឌា |
| ១៤ | The ASOSAI Seminar of Social Security Audit | ០១ នាក់ | ឥណ្ឌា |
| ១៥ | ជំនាញភាពជាអ្នកដឹកនាំ | ០៦ នាក់ | ជប៉ុន |
| ១៦ | IT Audit | ០២ នាក់ | ម៉ាឡេស៊ី |
| ១៧ | TeamMate audit software | ០៤ នាក់ | ម៉ាឡេស៊ី |
| | **ឆ្នាំ ២០១០** (ចំនួន ១៣ វគ្គ) | | |
| ១ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១ នាក់ | ម៉ាឡេស៊ី |
| ២ | សវនកម្មលើបរិស្ថាន | ០១ នាក់ | ឥណ្ឌា |
| ៣ | ការគ្រប់គ្រងធនធានមនុស្ស | ០៣ នាក់ | ថៃ |
| ៤ | យន្តការសម្របសម្រួលរវាងរដ្ឋសភា និងរដ្ឋាភិបាល | ០២ នាក់ | ឡាវ |
| ៥ | សវនកម្មលើកិច្ចប្រតិបត្តិការ និងតាមប្រព័ន្ធព័ត៌មានវិទ្យា | ០៣ នាក់ | ចិន |
| ៦ | សៀវភៅណែនាំសវនកម្ម | ០៣ នាក់ | ម៉ាឡេស៊ី |
| ៧ | គោលនយោបាយគ្រប់គ្រង | ០៥ នាក់ | ជប៉ុន |
| ៨ | សវនកម្មលើបរិស្ថាន | ០២ នាក់ | ចិន |

| | | | |
|---|---|---|---|
| ៩ | សវនកម្មលើវិស័យសាធារណៈ | ០១ នាក់ | កូរ៉េ |
| ១០ | សវនកម្មលើបរិស្ថាន | ០១ នាក់ | ទូគី |
| ១១ | បណ្តុះបណ្តាលស្តីពីគ្រូបង្គោល | ០៥ នាក់ | វៀតណាម |
| ១២ | បណ្តុះបណ្តាលស្តីពីជំនាញសម្របសម្រួល | ០៣ នាក់ | ថៃ |
| ១៣ | សវនកម្មលើសហគ្រាសសាធារណៈ | ០២ នាក់ | ឥណ្ឌា |
| ១៤ | សវនកម្មដោយប្រព័ន្ធព័ត៌មានវិទ្យា | ០២ នាក់ | ម៉ាឡេស៊ី |

### ៥.២- ការងារសិក្ខាសាលា

#### ៥.២.១- ការងារសិក្ខាសាលាថ្នាក់ជាតិ

ក្នុងរយៈពេល ១០ឆ្នាំនេះ អាជ្ញាធរសវនកម្មជាតិ បានបើកសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងសិក្ខាសាលាពាក់ព័ន្ធការងារសវនកម្មផ្សេងៗទៀត ដើម្បីផ្តល់ការយល់ដឹងឲ្យកាន់តែច្បាស់ពីច្បាប់នេះ ពីព្រោះការងារសវនកម្មសាធារណៈ គឺជាការងារថ្មីមិនធ្លាប់មាននៅព្រះរាជាណាចក្រកម្ពុជា។ ការងារសិក្ខាសាលាផ្សព្វផ្សាយច្បាប់នេះ ត្រូវបានរៀបចំជារៀងរាល់ឆ្នាំ តាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន និងបណ្តាអង្គភាពផ្សេងៗ ដូចខាងក្រោម៖

- **ឆ្នាំ ២០០៣**

សិក្ខាសាលាលើកដំបូង ក្រោមការឧបត្ថម្ភរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានភ្ញៀវចូលរួមមកពីគ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង បណ្តាស្ថានទូត អង្គការនានា និង អ្នកពាក់ព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា។







ឯកឧត្តម **អ៊ិត ឈន** មានប្រសាសន៍ ក្នុងពិធីបិទអង្គសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

- **ឆ្នាំ ២០០៦**
  - សិក្ខាសាលាស្តីពីការធ្វើសវនកម្មលើគម្រោងសាងសង់ ដែលផ្តល់បទឧទ្ទេសនាមដោយអ្នកឯកទេសជាន់ខ្ពស់មកពីស្ថាប័នសវនកម្មកំពូលអន្តរជាតិ
  - សិក្ខាសាលាស្តីពីការត្រួតពិនិត្យផ្ទៃក្រៅ នៃហិរញ្ញវត្ថុសាធារណៈ នៅរដ្ឋបឺន នៃប្រទេសស្វីស
  - សិក្ខាសាលាស្តីពីស្តង់ដារគណនេយ្យអន្តរជាតិសម្រាប់ការគ្រប់គ្រងរដ្ឋបាល និងវេទិកា សភាអន្តរជាតិ ស្តីពីការត្រួតពិនិត្យថវិកា។




ឯកឧត្តម **អ៊ិត ឈន** អញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងសិក្ខាសាលា ស្តីពីការត្រួតពិនិត្យផ្ទៃក្រៅនៃហិរញ្ញវត្ថុសាធារណៈ




ឯកឧត្តម **អ៊ិត ឈន** និងថ្នាក់ដឹកនាំ អ.ស.ជ អញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងសិក្ខាសាលា ស្តីពីការធ្វើសវនកម្មលើគម្រោងសាងសង់

- **ឆ្នាំ ២០០៧**
  - សិក្ខាសាលាស្តីពីការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ រយៈពេល ៥ឆ្នាំ (២០០៧-២០១១) របស់អាជ្ញាធរសវនកម្មជាតិ
  - សិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់ ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីសវនកម្មផ្ទៃក្នុង
  - សិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់ ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តកំពត។



ឯកឧត្តម **អ៊ុត ឈន** អគ្គសវនករ និងឯកឧត្តម **ហ៊ុន ណេង** អភិបាលខេត្តកំពង់ចាម
អញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងសិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់
ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកំពង់ចាម

- **ឆ្នាំ ២០០៨**
  - សិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តមណ្ឌលគីរី និងក្រុងប៉ៃលិន
  - សិក្ខាសាលាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។





ឯកឧត្តម **សេង រ៉ុន** អគ្គសវនកររង អញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់
ក្នុងសិក្ខាសាលាស្ដីពីការផ្សព្វផ្សាយច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
នៅខេត្តប៉ៃលិន

- **ឆ្នាំ ២០០៩**
    - សិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា នៅ ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តស្វាយរៀង និងខេត្តមណ្ឌលគីរី
    - សិក្ខាសាលាស្តីពីការធ្វើឲ្យប្រសើរកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ តាមរយៈ ការងារសវនកម្មផ្ទៃក្រៅ។
- **ឆ្នាំ ២០១០**
    - សិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តរតនគីរី ខេត្តក្រចេះ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តកណ្តាល និងខេត្តព្រះវិហារ
    - សិក្ខាសាលាស្តីពីការធ្វើឲ្យប្រសើរកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ តាមរយៈ សហប្រតិបត្តិការរវាងអាជ្ញាធរសវនកម្មជាតិ ជាមួយសវនកម្មផ្ទៃក្នុង
    - សិក្ខាសាលាស្តីពីសវនកម្មលើកម្មវិធីកិច្ចសន្យាអ្នកទទួលជំនួយសហរដ្ឋអាមេរិក។





ឯកឧត្តម **ឆាយ គឹម** អគ្គសវនករងរង អញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុង សិក្ខាសាលា ស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកំពង់ធំ

### ៥.២.២- ការចូលរួមសិក្ខាសាលា និងធ្វើទស្សកិច្ចសិក្សានៅបរទេស

ក្រៅពីការរៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយច្បាប់ ថ្នាក់ដឹកនាំជាន់ខ្ពស់បានអញ្ជើញទៅចូលរួមក្នុងកម្មវិធីសិក្ខាសាលានៅបរទេស ដូចជា៖

| ល.រ | កម្មវត្ថុនៃការចូលរួម | ប្រតិភូដឹកនាំ | ទីកន្លែង |
|---|---|---|---|
| | **ឆ្នាំ ២០០៣** | | |
| ១ | ទស្សនកិច្ចសិក្សា | អគ្គលេខាធិការ | ប្រទេសម៉ាឡេស៊ី |
| ២ | ទស្សនកិច្ចសិក្សាទាក់ទងការងារសវនកម្ម | អគ្គសវនកររង | ប្រទេសសិរីលង្កា |
| | **ឆ្នាំ ២០០៤** | | |
| ៣ | សិក្ខាសាលាស្តីពីភាពឯករាជ្យ នៃស្ថាប័នសវនកម្ម | ឯ.ឧ អ៊ុត ឈន | ប្រទេសអូទ្រីស |
| | **ឆ្នាំ ២០០៨** | | |
| ៤ | សិក្ខាសាលាស្តីពីសវនកម្មលើបរិស្ថាន | អគ្គលេខាធិការ | ប្រទេសចិន |
| | **ឆ្នាំ ២០១០** | | |
| ៥ | សិក្ខាសាលាស្តីពីយន្តការសម្របសម្រួលរវាងរដ្ឋសភា និងរដ្ឋាភិបាលក្នុងសវនកម្មរដ្ឋ | អគ្គលេខាធិការ | ប្រទេសវៀតណាម |
| ៦ | សិក្ខាសាលាពាក់ព័ន្ធការងារគណនេយ្យអន្តរជាតិ | អគ្គលេខាធិការរង | ប្រទេសស្វីស |

## ៦- ការងារសហប្រតិបត្តិការ

ការងារសហប្រតិបត្តិការ ជាមួយស្ថាប័នថ្នាក់ជាតិ ក៏ដូចជាមួយថ្នាក់អន្តរជាតិ គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយនៃផ្នែកគាំទ្រ ក្នុងន័យជំរុញឲ្យការងារអនុវត្តលើគ្រប់ផ្នែក នៃកិច្ចប្រតិបត្តិការសវនកម្មទទួលបានប្រសិទ្ធភាពខ្ពស់ និងមានការអភិវឌ្ឍន៍ឈានឡើងស្របជាមួយគោលនយោបាយ និងកម្មវិធីកែទម្រង់លើគ្រប់វិស័យរបស់រាជរដ្ឋាភិបាលផង និងស្របជាមួយដំណើរអភិវឌ្ឍន៍ឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃរបស់ស្ថាប័នសវនកម្មកំពូលនានា ទាំងនៅក្នុងតំបន់ និងនៅលើសាកលលោក។

កិច្ចខិតខំប្រឹងប្រែងលើការងារនេះ មានដូចតទៅ៖

### ៦.១- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ

#### ៦.១.១- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្បញ្ញត្តិ

- ចូលរួមប្រជុំនានាជាមួយតំណាងរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាទាក់ទងដល់វិស័យសេដ្ឋកិច្ចជាតិ
- បានចូលប្រជុំជាមួយគណៈកម្មការទី២ នៃរដ្ឋសភា និងគណៈកម្មការទី២ នៃព្រឹទ្ធសភាទាក់ទងនឹងការងារសវនកម្ម និងការងាររៀបចំច្បាប់ទាក់ទងបញ្ហាសេដ្ឋកិច្ច ហិរញ្ញវត្ថុផ្សេងៗ។

#### ៦.១.២- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្រតិបត្តិ

- បានចូលរួមប្រជុំពិភាក្សាលើការងាររៀបចំឯកសារគតិយុត្តិមួយចំនួន ពាក់ព័ន្ធការងារហិរញ្ញវត្ថុសាធារណៈ

- បានចូលរួមប្រជុំពិភាក្សាការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយចំនួនពាក់ព័ន្ធជាមួយដៃគូអភិវឌ្ឍន៍
- បានចូលរួមសកម្មភាពសម្ពោធសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល
- ចូលរួមពិធីចែកសញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី។

**៦.១.៣- ការចូលរួមការងារសង្គម**

- ឯកឧត្តម **អ៊ុត ឈន** និង**លោកជំទាវ** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការបានចូលរួមធ្វើបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារវត្ត**បទុមពិសី ហៅវត្តល្វាលើ** និងសមិទ្ធិផលនានា ព្រមទាំងពិធីសម្ពោធវិទ្យាល័យ **ប៊ុន រ៉ានី ហ៊ុន សែន** កោះដាច់ និងអគារសិក្សា ៨ខ្នង នៅភូមិល្វា ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល នាថ្ងៃទី២៥-២៨ ខែមករា ឆ្នាំ២០១០



វិទ្យាល័យ **ប៊ុន រ៉ានី ហ៊ុន សែន** កោះដាច់ និងអគារសិក្សា ៨ខ្នង នៅភូមិល្វា ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល



ព្រះវិហារវត្តបទុមពិសី **ហៅវត្តល្វាលើ** និងសមិទ្ធិផលនានានៅភូមិល្វា ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល

- ឯកឧត្តម **អ៊ុត ឈន** និង**លោកជំទាវ** និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ បានអញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយជូនកងទ័ពឈរជើងនៅសមរភូមិមុខនៅតំបន់ប្រាសាទព្រះវិហារ នាថ្ងៃទី៣-៤ ខែកញ្ញា ឆ្នាំ២០១១។







ឯកឧត្តម **អ៊ុត ឈន និងលោកជំទាវ** ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការបាន អញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយជូនកងទ័ពឈរជើងនៅសមរភូមិមុខនៅ តំបន់ប្រាសាទព្រះវិហារ

### ៦.២- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសវនកម្មកំពូលអន្តរជាតិ

ក្នុងការធ្វើឲ្យសម្រេចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ក្រៅពីមានការគាំទ្រពីសំណាក់ស្ថាប័នកំពូលថ្នាក់ជាតិ អាជ្ញាធរសវនកម្មជាតិ បានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាដៃគូអភិវឌ្ឍន៍អន្តរជាតិក្នុងតំបន់ និងស្ថាប័នសវនកម្មកំពូលអន្តរជាតិនានាទៀត មានដូចជា៖

#### ៦.២.១- ការចូលជាសមាជិកអង្គការអន្តរជាតិ

អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិកអង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល (INTOSAI) នៅក្នុង**ខែធ្នូ ឆ្នាំ២០០២** ដែលបច្ចុប្បន្នមានសមាជិកសរុបចំនួន ១៨៩ប្រទេស។ នៅក្នុង**ខែមីនា ឆ្នាំ២០០៤** អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិកអង្គការអាស៊ី នៃស្ថាប័នសវនកម្មកំពូល (ASOSAI) បច្ចុប្បន្នមានសមាជិកសរុបចំនួន ៤៥ប្រទេស។

ការចូលជាសមាជិកអង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល និងអាស៊ី ផ្តើមចេញពីការប្រមូលផ្តុំ នៃស្ថាប័នសវនកម្មកំពូលតាមបណ្តាប្រទេស សំដៅពង្រឹងគោលការណ៍សវនកម្មស្តង់ដារសវនកម្ម និងផ្តល់នូវបទពិសោធន៍តាមរយៈការបំពេញទស្សនកិច្ចសិក្សា ការបណ្តុះបណ្តាល និងកិច្ចសហប្រតិបត្តិការនានា លើវិស័យសវនកម្មផ្ទៃក្រៅ ដើម្បីរួមចំណែកថែរក្សានូវសុវត្ថិភាពការងារជំនាញឲ្យសមស្របតាមកម្រិតស្តង់ដារអន្តរជាតិ។

អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(INTOSAI) បានបង្កើតឡើងនៅឆ្នាំ១៩៥៣រួមមានសមាគមន៍ ចំនួន ៧រួមមាន ៖

(1)- Organization of Latin American and Caribbean Supreme Audit Institutions (OLACEFS), បង្កើតឡើងនៅឆ្នាំ១៩៦៥

(2)- African Organization of Supreme Audit Institutions (AFROSAI), បង្កើតឡើងនៅឆ្នាំ ១៩៧៦

(3)- Arab Organization of Supreme Audit Institutions (ARABOSAI), បង្កើតឡើងនៅឆ្នាំ ១៩៧៦

(4)- Asian Organization of Supreme Audit Institutions (ASOSAI), បង្កើតឡើងនៅឆ្នាំ ១៩៧៨

(5)- Pacific Association of Supreme Audit Institutions (PASAI), បង្កើតឡើងនៅឆ្នាំ ១៩៨៧

(6)- Caribbean Organization of Supreme Audit Institutions (CAROSAI), បង្កើតឡើងនៅឆ្នាំ ១៩៨៨

(7)- European Organization of Supreme Audit Institutions (EUROSAI), បង្កើតឡើងនៅឆ្នាំ ១៩៩០។

ជាមួយនេះ អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិកក្រុមការងារបច្ចេកទេស នៃការធ្វើសវនកម្មតាមប្រព័ន្ធព័ត៌មានវិទ្យា (Working Group on IT audit) នៃអង្គការ INTOSAI និងចូលជា

សមាជិកក្រុមការងារបច្ចេកទេស នៃការចងក្រងឯកសារស្តីពីតម្លៃ និងអត្ថប្រយោជន៍របស់បណ្តាស្ថាប័នសវនកម្មកំពូលនានា(Working Group in Value and Benefit of SAIs) នៃអង្គការ INTOSAI ។

### ៦.២.២- សកម្មភាពទំនាក់ទំនងជាលក្ខណៈអន្តរជាតិ

ថ្នាក់ដឹកនាំជាន់ខ្ពស់អាជ្ញាធរសវនកម្មជាតិ បានអញ្ជើញចូលរួមប្រជុំជាមួយបណ្តាដៃគូអភិវឌ្ឍន៍ បណ្តាស្ថាប័នសវនកម្មកំពូលនានានៅលើសាកលលោក និងចូលរួមសិក្ខាសាលាថ្នាក់អន្តរជាតិជាច្រើន មានដូចជា៖

| ល.រ | កម្មវត្ថុនៃការចូលរួម | ប្រតិភូដឹកនាំ | ទីកន្លែង |
|---|---|---|---|
| | **ឆ្នាំ ២០០៣** | | |
| ១ | ចូលរួម សន្និសីទស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការពារសច្ចៈភាព | ឯ.ឧ អ៊ុត ឈន | សាធារណរដ្ឋកូរ៉េ |
| ២ | ចូលរួមសន្និបាតស្ថាប័នសវនកម្មកំពូលអាស៊ីលើកទី៩ | ឯ.ឧ អ៊ុត ឈន | ប្រទេសហ្វីលីពីន |
| | **ឆ្នាំ ២០០៤** | | |
| ១ | ចូលរួមប្រជុំការងារស្តីពីការប្រឆាំងអំពើពុករលួយជាមួយ Mr. Bertrand De Speville (អតីតស្នងការនៃគណៈកម្មាធិការប្រឆាំងអំពើពុករលួយនៅហុងកុង (ICAC) និងជាទីប្រឹក្សា នៃក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយប្រចាំអឺរ៉ុប) | ឯកឧត្តម អគ្គលេខាធិការ | អ.ស.ជ |
| ២ | ចូលរួមប្រជុំអន្តរជាតិលើកទី១៨ | ឯកឧត្តម លុក ញ៉ិប | ប្រទេសហុងគ្រី |
| | **ឆ្នាំ ២០០៥** | | |
| ១ | ចូលរួមប្រជុំស្តីពីការពង្រឹងលើកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរសវនកម្មជាតិជាមួយអង្គការសហប្រតិបត្តិការបច្ចេកវិទ្យាអាល្លឺម៉ង់ (GTZ) | ឯ.ឧ អ៊ុត ឈន | អ.ស.ជ |
| ២ | បានចូលរួមប្រជុំពិភាក្សាការងារ ជាមួយ GTZ និងតំណាងអង្គការ InWent ស្តីពីលទ្ធភាពបញ្ជូនមន្ត្រីនៃ អ.ស.ជ ទៅបណ្តុះបណ្តាល | | ប្រទេសអាល្លឺម៉ង់ |
| | **ឆ្នាំ ២០០៦** | | |
| ១ | បានចូលរួមប្រជុំជាមួយធនាគារអភិវឌ្ឍន៍អាស៊ី | ឯ.ឧ អ៊ុត ឈន | អ.ស.ជ |

| | | | |
|---|---|---|---|
| | ធនាគារពិភពលោក មូលនិធិរូបិយប័ណ្ណអន្តរជាតិ DANIDA អង្គការ Action Aid International អង្គការ Target EC Support to Pro-poor Basic Education Reforms in Cambodia និង មន្ត្រីតំណាងស្ថានទូតស៊ុយអ៊ែត ប្រចាំនៅកម្ពុជា | | |
| ២ | ចូលរួមសន្និបាត ASOSAI លើកទី១០ | ឯ.ឧ អ៊ុត ឈន | ប្រទេសចិន |
| ៣ | គណៈប្រតិភូជាន់ខ្ពស់នៃសវនកម្មកំពូលសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានអង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល(ASOSAI) អញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ | ឯកឧត្តម **លី ជិនហួរ** អគ្គសវនករ | ប្រទេសកម្ពុជា |
| ៤ | គណៈប្រតិភូ អញ្ជើញមកចូលរួមប្រជុំស្តីពីការរៀបចំអ្នកបង្ហាត់បង្ហាញសម្រាប់ធ្វើសិក្ខាសាលាលើកទី ២ នៃកម្មវិធីសហប្រតិបត្តិការ (ADB-IDI-ASOSAI) | ស្ថាប័នសវនកម្មកំពូលចំនួន ១៦ប្រទេស | ប្រទេសកម្ពុជា |
| ៥ | គណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ | ស្ថាប័នសវនកម្មកំពូលម៉ាឡេស៊ី | ប្រទេសកម្ពុជា |
| | **ឆ្នាំ ២០០៧** | | |
| ១ | គណៈប្រតិភូជាន់ខ្ពស់នៃស្ថាប័នកំពូលប្រទេសវៀតណាម អញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ | ឯ.ឧ Vuong Dinh Hue អគ្គសវនករ | ប្រទេសកម្ពុជា |
| ២ | អាជ្ញាធរសវនកម្មជាតិ បានទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំ ស្តីពីការរៀបចំផែនការសម្រាប់កម្មវិធីធានាគុណភាពសវនកម្មរបស់អង្គការ IDI-ASOSAI | ស្ថាប័នសវនកម្មកំពូលចំនួន ១០ប្រទេស | ប្រទេសកម្ពុជា |
| ៣ | អគ្គសវនករអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ | ឯ.ឧ អ៊ុត ឈន | ប្រទេសចិន |
| ៤ | ថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ INTOSAI លើកទី១៩ នៅទីក្រុងវីយ៉ែន | ឯ.ឧ អ៊ុត ឈន | ប្រទេសអូទ្រីស |
| ៥ | ថ្នាក់ដឹកនាំជាន់ខ្ពស់នៃអាជ្ញាធរសវនកម្មជាតិបានជួបប្រជុំពិភាក្សាការងារមួយចំនួនជាមួយតំណាងអង្គការក្រៅរដ្ឋាភិបាលនានា ទាក់ទងកម្មវិធីកិច្ចសហប្រតិបត្តិការយូរអង្វែង | | ប្រទេសកម្ពុជា |

| | | | |
|---|---|---|---|
| | **ឆ្នាំ ២០០៨** | | |
| ១ | គណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការស្តីពីការប្រឆាំងអំពើពុករលួយនៅអាស៊ី | ឯ.ឧ អ៊ុត ឈន | ប្រទេសកាតា |
| ២ | គណៈប្រតិភូជាន់ខ្ពស់អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ | ឯ.ឧ អ៊ុត ឈន | ប្រទេសវៀតណាម និងឡាវ |
| ៣ | គណៈប្រតិភូនៃអាជ្ញាធរសវនកម្មជាតិ បានអញ្ជើញទៅចូលរួមសមាជលើកទី ១៩ នៃអង្គការ INCOSAI | ឯ.ឧ ឆាយ គឹម | ប្រទេសម៉ិចស៊ិកូ |
| ៤ | ថ្នាក់ដឹកនាំជាន់ខ្ពស់នៃអាជ្ញាធរសវនកម្មជាតិបានជួបប្រជុំពិភាក្សាការងារជាមួយដៃគូអភិវឌ្ឍន៍មួយចំនួន ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព ស្ថាប័នឲ្យរឹងមាំថែមទៀត | | ប្រទេសកម្ពុជា |
| | **ឆ្នាំ ២០០៩** | | |
| ១ | គណៈប្រតិភូជាន់ខ្ពស់នៃស្ថាប័នសវនកម្មកំពូលឡាវអញ្ជើញមកបំពេញទស្សកិច្ចជាផ្លូវការ | ឯ.ឧ បូស៊ី ឡាវ៉ាន់សៃ អគ្គសវនករ | ប្រទេសកម្ពុជា |
| ២ | គណៈប្រតិភូជាន់ខ្ពស់របស់អាជ្ញាធរសវនកម្មជាតិអញ្ជើញធ្វើទស្សនកិច្ចជាផ្លូវការនៅក្រៅប្រទេស | ឯ.ឧ អ៊ុត ឈន | ប្រទេសអង់គ្លេស ឥណ្ឌា, ញូហ្សេឡែន |
| ៣ | គណៈប្រតិភូនៃអាជ្ញាធរសវនកម្មជាតិ បានអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ | ឯ.ឧ សេង រ៉ុន អគ្គសវនកររង | ប្រទេសវៀតណាម |
| | **ឆ្នាំ ២០១០** | | |
| ១ | អញ្ជើញចូលរួមប្រជុំក្រុមការងារសវនកម្មដោយប្រព័ន្ធព័ត៌មានវិទ្យារបស់អង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូលលើកទី ១៩ និងចូលរួមក្នុងកិច្ចប្រជុំក្រុមការងារសវនកម្ម ស្តីពីកិច្ចប្រតិបត្តិការរបស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូលលើកទី ៦ នៅទីក្រុងប៉េកាំង | ឯ.ឧ អ៊ុត ឈន | ប្រទេសចិន |
| ២ | អគ្គសវនករអញ្ជើញចូលរួមមហាសន្និបាតលើកទី ២០ របស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូលនៅទីក្រុងJohannesburg | ឯ.ឧ អ៊ុត ឈន | ប្រទេសអាហ្វ្រិកខាងត្បូង |
| ៣ | អគ្គសវនកររងអញ្ជើញចូលរួមប្រជុំពិភាក្សាលើកិច្ចព្រមព្រៀង លើកិច្ចប្រតិបត្តិស្តីពីការធានាគុណភាពសវនកម្មលើកិច្ចប្រតិបត្តិការ | ឯ.ឧ ឆាយ គឹម | ប្រទេសវៀតណាម |

### ៦.២.៣- ការចុះកិច្ចព្រមព្រៀងអនុស្សរណៈ នៃការយោគយល់គ្នា

ក្នុងការអភិវឌ្ឍន៍នាពេលកន្លងមក រួមទាំងលទ្ធផលស្តែងចេញពីការខិតខំប្រឹងប្រែងលើគ្រប់វិស័យការងារដែលរួមមានជាអាទិ៍៖ ការផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធវិជ្ជាជីវៈសវនកម្ម ការបណ្តុះបណ្តាលនានា ជាមួយបណ្តាប្រទេសជាសមាជិកអង្គការសវនកម្មកំពូលអាស៊ី និងអន្តរជាតិ។ល។ អាជ្ញាធរសនវកម្មជាតិ បានទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាលចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយបណ្តាប្រទេសមួយចំនួន ក្នុងគោលបំណងបង្កើនសមត្ថភាពរបស់មន្ត្រីនិងពង្រឹងការងារអាជ្ញាធរសវនកម្មជាតិឲ្យបានរឹងមាំ។

ក្នុងរយៈពេល១០ឆ្នាំនេះ អាជ្ញាធរសវនកម្មជាតិបានចុះហត្ថលេខាលើអនុស្សារណៈ នៃការយោគយល់គ្នាជាមួយបណ្តាស្ថាប័នសវនកម្មកំពូលនានាបានចំនួន ០៧ មានដូចជា៖

- ចុះហត្ថលេខាលើអនុស្សារណៈ នៃការយោគយល់គ្នា ជាមួយស្ថាប័នសវនកម្មកំពូលនៃសាធារណរដ្ឋប្រជាមានិតចិន នៅទីក្រុងប៉េកាំង នាថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧។



ឯកឧត្តម **អ៊ិត ឈន** ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយ ឯកឧត្តម **លី ជិនហួរ** អគ្គសវនករនៃស្ថាប័នសវនកម្មកំពូលសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧ នៅទីក្រុងប៉េកាំង ប្រទេសចិន

- ចុះហត្ថលេខាលើអនុស្សារណៈ នៃការយោគយល់គ្នា ជាមួយស្ថាប័នសវនកម្មកំពូលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅទីក្រុងហាណូយ នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨។




ឯកឧត្តម **អ៊ុត ឈន** ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយ ឯកឧត្តម **Vuong Dinh Hue** អគ្គសវនករនៃស្ថាប័នសវនកម្មកំពូលវៀតណាម កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ នៅទីក្រុងហាណូយប្រទេសវៀតណាម

- ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័នសវនកម្មកំពូលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅរាជធានីភ្នំពេញ នាថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។



ឯកឧត្តម **អ៊ុត ឈន** ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយឯកឧត្តម បូស៊ី ឡាវ៉ាន់សៃ អគ្គសវនករឡាវ នៅព្រះរាជាណាចក្រកម្ពុជា

- ចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាជាមួយស្ថាប័នសវនកម្មកំពូលនៃប្រទេសនូវែលហ្សឺឡង់ នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ នៅប្រទេសនូវែលហ្សឺឡង់ ។ ការចុះហត្ថលេខានេះ មានគោលបំណងធ្វើការត្រួតពិនិត្យបច្ចេកទេស ដើម្បីវាយតម្លៃ

លើទំហំ ការងារសវនកម្ម និងការគ្រប់គ្រងរបស់អាជ្ញាធរសវនកម្មជាតិ ដោយឆ្លុះបញ្ចាំងនូវស្តង់ដារវិជ្ជាជីវៈ ដែលមានការទទួលស្គាល់ជាអន្តរជាតិ។



ឯកឧត្តម **អ៊ុត ឈន** ជួបពិភាក្សាការងារជាមួយតំណាងស្ថាប័នសវនកម្មកំពូលនៃប្រទេសនូវែលហ្សេឡង់ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

- ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយស្ថាប័នសវនកម្មកំពូលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី នៅប្រទេសអាហ្វ្រិកខាងត្បូង នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១០។



ឯកឧត្តម **អ៊ុត ឈន** ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយឯកឧត្តម Hadi Poernomo ប្រធានក្រុមប្រឹក្សាសវនកម្ម សាធារណរដ្ឋ ឥណ្ឌូនេស៊ី នៅទីក្រុង Johannesburg ប្រទេសអាហ្វ្រិកខាងត្បូង

- ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័នសវនកម្មកំពូលនៃសាធារណរដ្ឋឥណ្ឌានាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា





ឯកឧត្តម **អ៊ុត ឈន** ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយឯកឧត្តម **រ៉ាជេស កុមារ ស័កដេវ៉** ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌា ក្នុងនាម អគ្គត្រួតពិនិត្យ និងអគ្គសវនករ ការិយាល័យអគ្គត្រួតពិនិត្យ និងអគ្គសវនករ នៃសាធារណរដ្ឋឥណ្ឌា

- ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័នសវនកម្មជាតិនៃប្រទេសស៊ុយអ៊ែត នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



ឯកឧត្តម **អ៊ុត ឈន** ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយឯកឧត្តម **Jan Landahl** អគ្គសវនករនៃស្ថាប័នសវនកម្មជាតិនៃប្រទេសស៊ុយ អ៊ែត នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

- ចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចប្រជុំរវាងថ្នាក់ដឹកនាំនៃស្ថាប័នសវនកម្មរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម អាជ្ញាធរសវនកម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នសវនកម្មរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម
- ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរសវនកម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជានិងសមាគមវិជ្ជាជីវៈគណនេយ្យករអេស៊ីស៊ីអេ (ACCA) នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយ IDI-ASOSAI ស្តីពីៈ
    - ការធានាគុណភាពសវនកម្មលើការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
    - ការធានាគុណភាពសវនកម្មលើការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការនៅប្រទេសវៀតណាម នាថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១០
    - ការរៀបចំ និងការអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រ IDI ASOSAI ២០១១-២០១៤ នាថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១១ នៅទីក្រុងIstanbul ប្រទេសទួគី។




ឯកឧត្តម **អ៊ិត ឈន** ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ ASOSAI IDI
ស្តីពីកម្មវិធីធានាគុណភាពសវនកម្ម ២០០៧-២០០៨ជាមួយតំណាង IDI
ព្រមទាំងតំណាងស្ថាប័នសវនកម្មកំពូលចំនួន ៩
នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា




ឯកឧត្តម **អ៊ិត ឈន** ចូលរួមក្នុងកិច្ចប្រជុំផែនការយុទ្ធសាស្ត្រ IDI ASOSAI ២០១១-២០១៤
ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១១ នៅទីក្រុង Istanbul ប្រទេសទួគី

### ៦.២.៤- គម្រោងគាំទ្ររបស់ដៃគូអភិវឌ្ឍន៍

ក្នុងការពង្រឹង និងពង្រីកការទទួលខុសត្រូវរបស់អាជ្ញាធរសវនកម្មជាតិ លើវិស័យសវនកម្មសាធារណៈ។ អាជ្ញាធរសវនកម្មជាតិ បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងកម្មវិធីជំនួយលើគម្រោងគាំទ្រមួយចំនួនជាមួយជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) GTZ (បច្ចុប្បន្ន GIZ) ធនាគារ ពិភពលោក (WB) និងDANIDA។



ថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិជួបប្រជុំពិភាក្សាការងារជាមួយដៃគូអភិវឌ្ឍន៍
នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ អាជ្ញាធរសវនកម្មជាតិ

- **គម្រោងនៃកិច្ចសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)**

លទ្ធផលសម្រេចបានលើការចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ រួមមាន៖

- បានរៀបចំដំណើរការទស្សនកិច្ចសិក្សាទៅបរទេសចំនួន ០២លើក
- បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន ០៨វគ្គ
- ជួយដល់ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តន៍ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- ជួយដល់ការរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីនីតិវិធី ទំនាក់ទំនងរវាងអាជ្ញាធរសវនកម្មជាតិ ជាមួយគណៈកម្មការទី២ នៃរដ្ឋសភា
- ជួយដល់ការរៀបចំសៀវភៅណែនាំការធ្វើសវនកម្មលើគំរោងឥណទានក្រៅប្រទេស
- ជួយដល់ការធ្វើសវនកម្មសាកល្បងចំនួន០៤លើក
- បានឧបត្ថម្ភកុំព្យូទ័រយួរដៃចំនួន០៥គ្រឿង
- បានឧបត្ថម្ភរថយន្តម៉ាក Prado ចំនួន០១គ្រឿង។



ឯកឧត្តម **អ៊ុត ឈន** និងថ្នាក់ដឹកនាំ អ.ស.ជ ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង
កិច្ចសហប្រតិបត្តិការជាមួយលោក KUNIO SENGA អគ្គនាយក ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)
ប្រចាំនៅអាស៊ីអាគ្នេយ៍
នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

- **គម្រោងនៃកិច្ចសហប្រតិបត្តិការរបស់ GTZ** (បច្ចុប្បន្ន GIZ)

លទ្ធផលសម្រេចបានពីការចុះកិច្ចព្រមព្រៀងសហប្រតិការ រួមមាន ៖

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០០៧-២០១១)
- សៀវភៅណែនាំការគ្រប់គ្រងធនធានមនុស្ស
- សៀភៅណែនាំការបណ្តុះបណ្តាល
- បាន និងកំពុងរៀបចំសៀវភៅណែនាំសវនកម្មស្តីពីការធ្វើសវនកម្មលើធនាគារ
- ទស្សនកិច្ចសិក្សា និងការចូលរួមផ្លាស់ប្តូរបទពិសោធន៍នៅតាមស្ថាប័នសវនកម្មកំពូលអន្តរជាតិនានា
- ចូលរួមសិក្ខាសាលា និងសន្និសីទនានាដែលរៀបចំដោយ INTOSAI និង ASOSAI
- មន្ត្រីចំនួន ០៤រូប ទៅបណ្តុះបណ្តាលនៅប្រទេសអាល្លឺម៉ង់រយៈពេល ១ឆ្នាំ
- បើកវគ្គបណ្តុះបណ្តាលជំនាញនានា ពាក់ព័ន្ធការងារសវនកម្មនៅក្នុងប្រទេស និងក្រៅប្រទេស
- ផ្គត់ផ្គង់ឧបករណ៍ព័ត៌មានវិទ្យា: កុំព្យូទ័រ (Desktop) ចំនួន១៣គ្រឿង និង LCD Projector ចំនួន ០១គ្រឿង

- បោះពុម្ពសៀវភៅ និង ឯកសារពាក់ព័ន្ធជំនាញសវនកម្មចំនួន ០៩ភាគ
- ឧបត្ថម្ភដល់មន្ត្រីក្នុងការបណ្តុះបណ្តាលភាសាអង់គ្លេស
- គោលការណ៍ណែនាំស្តីពីរបៀបសរសេររបាយការណ៍ផ្សព្វផ្សាយជាសាធារណៈ
- ស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា។



ឯកឧត្តម **អ៊ុត ឈន** និងថ្នាក់ដឹកនាំ អ.ស.ជ ក្នុងពិធីចុះហត្ថលេខាលើគម្រោងកិច្ចសហប្រតិបត្តិការជាមួយលោក Heinrich Jürgen Schilling នាយក GIZ ប្រចាំព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

- **គម្រោងនៃកិច្ចសហប្រតិបត្តិការរបស់ធនាគារពិភពលោក** (WB)

លទ្ធផលសម្រេចបានរួមមាន៖

- ផ្តល់សេវាទីប្រឹក្សាអន្តរជាតិចំនួន ០១នាក់ និងក្នុងស្រុកចំនួន ០២នាក់
- រៀបចំសិក្ខាសាលាចំនួន ០៤
- រៀបចំវគ្គបណ្តុះបណ្តាលចំនួន ០៥វគ្គ
- ផ្គត់ផ្គង់ឧបករណ៍ព័ត៌មានវិទ្យា: LCD Projector ចំនួន០១គ្រឿង កុំព្យូទ័រ (Desktop) ចំនួន០៥គ្រឿង Printer ចំនួន០១គ្រឿង និង External hard-disks ចំនួន០២។

- **គម្រោងនៃកិច្ចសហប្រតិបត្តិការរបស់ DANIDA**

លទ្ធផលសម្រេចបានរួមមាន៖

- ជួយក្នុងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នសវនកម្មកំពូលនានា ដូចជា: ស្ថាប័នសវនកម្មកំពូលប្រទេសម៉ាឡេស៊ី វៀតណាម និងឡាវ
- ជួយបង្កើនការយល់ដឹងអំពីតួនាទី មុខងារ និងភារកិច្ចរបស់អាជ្ញាធរសវនកម្មជាតិ តាមរយៈសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

ទូទាំង២០ខេត្ត
- ជួយដល់ការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យ
- ឧបត្ថម្ភការប្រើប្រាស់ Internet និងការភ្ជាប់បណ្តាញកាប្លិ៍អុបទិច ជាមួយ NiDA
- ឧបត្ថម្ភកម្មវិធីគ្រប់គ្រងការងារសវនកម្មតាមប្រព័ន្ធព័ត៌មានវិទ្យា Team Mate
- ឧបត្ថម្ភការចូលរួមសិក្ខាសាលានៅប្រទេសស្វីស អាហ្វ្រិកខាងត្បូង និងប្រទេសម៉ាឡេស៊ី
- ឧបត្ថម្ភដល់ការបណ្តុះបណ្តាលស្តីពី ស្តង់ដារគណនេយ្យ មូលដ្ឋានច្បាប់ ស្ថិតិ ការគ្រប់គ្រង និងកិច្ចសន្យា
- ឧបត្ថម្ភដល់ការធ្វើទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅស្ថាប័នសវនកម្មកំពូលប្រទេសម៉ាឡេស៊ី
- ឧបត្ថម្ភការបង្កើត website និងIntranet
- ឧបត្ថម្ភឧបករណ៍ព័ត៌មានវិទ្យា ដូចជា: កុំព្យូទ័រ Desk top ចំនួន ០៥គ្រឿង កុំព្យូទ័រយួរដៃ ចំនួន ៧៥គ្រឿង ម៉ាស៊ីន Photo copy ចំនួន ០៥គ្រឿង និងឧបករណ៍មួយចំនួនទៀត។



ឯកឧត្តម **អ៊ុត ឈន** និង ថ្នាក់ដឹកនាំ អ.ស.ជ ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយលោក Tom Barthel Hansen ប្រធានស្ថានតំណាងនៃស្ថានទូតដាណាម៉ាក ប្រចាំទីក្រុងភ្នំពេញ
នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ៧- ការខាររដ្ឋបាលទូទៅ

ដោយការប្តេជ្ញាចិត្តដ៏មោះមុតក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ អាជ្ញាធរសវនកម្មជាតិ បានទទួលអគារការិយាល័យមួយកន្លែងដូចបានបញ្ជាក់ទីតាំងពីខាងដើម និងបានទទួលកញ្ចប់ថវិកាសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ ទោះជាយ៉ាងណាថវិកាជាតិដែលទទួលបានបច្ចុប្បន្ន ក៏ដូចរៀងរាល់ឆ្នាំកន្លងមក នៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការជាក់ស្តែងនៅឡើយ ដែលចំពោះមុខនៅខ្វះខាតសម្ភារបច្ចេកទេសជាច្រើនទៀតសម្រាប់ប្រើប្រាស់បានសមស្រប។

### ៧.១ ការគ្រប់គ្រងមន្ត្រីរាជការ

#### ៧.១.១- ស្ថិតិមន្ត្រីរាជការ

ចាប់តាំងពីឆ្នាំ២០០១ ដល់ឆ្នាំ២០១១ ស្ថានភាពមន្ត្រីរាជការមានដូចខាងក្រោម៖

| ឆ្នាំ | ចំនួនសរុប | អគ្គសវនករ និង អគ្គសវនកររង | អគ្គលេខាធិការ និង អគ្គលេខាធិការរង | ប្រធាន នាយកដ្ឋាន | អនុប្រធាន នាយកដ្ឋាន | ប្រធាន ការិយាល័យ | អនុប្រធាន ការិយាល័យ | មន្ត្រី |
|---|---|---|---|---|---|---|---|---|
| ២០០១ | **០៦នាក់** | ០៣ | ០២ | ០១ | - | - | - | - |
| ២០០២ | **៨៨នាក់**<br>ស្រី ០៩នាក់ | ០៣ | ០២ | ០២ | - | ០២ | ០៨ | ៧១ |
| ២០០៣ | **១៥៩នាក់**<br>ស្រី ៣២នាក់ | ០៣ | ០២ | ០២ | ០៥ | ០៧ | ១៦ | ១២៤ |
| ២០០៤ | **១៥៦នាក់**<br>ស្រី ៣០នាក់ | ០៣ | ០២ | ០២ | ០៥ | ០៨ | ១៦ | ១២០ |
| ២០០៥ | **១៥៥នាក់**<br>ស្រី ៣០នាក់ | ០៣ | ០៣ | ០៥ | ១០ | ០៧ | ២៥ | ១០២ |
| ២០០៦ | **២២៤នាក់**<br>ស្រី ៤៧នាក់ | ០៣ | ០២ | ០៥ | ១០ | ១៤ | ៤០ | ១៥០ |
| ២០០៧ | **២២៥នាក់**<br>ស្រី ៤៧នាក់ | ០៣ | ០៣ | ០៥ | ១០ | ១៤ | ៤០ | ១៥០ |
| ២០០៨ | **២២១នាក់**<br>ស្រី ៤៨នាក់ | ០៣ | ០៣ | ០៥ | ១០ | ២០ | ៥២ | ១២៨ |
| ២០០៩ | **២១៤នាក់**<br>ស្រី ៤៦នាក់ | ០៣ | ០៣ | ០៥ | ១០ | ២០ | ៥០ | ១២៣ |
| ២០១០ | **២០៧នាក់**<br>ស្រី ៤៥នាក់ | ០៣ | ០៣ | ០៥ | ១២ | ២៣ | ៥១ | ១១០ |
| ២០១១ | **២០១នាក់**<br>ស្រី ៤២នាក់ | ០៣ | ០៤ | ០៥ | ២៤ | ២៦ | ៦៨ | ៧១ |

**បញ្ជាក់ ៖** រាល់ការជ្រើសរើសមន្ត្រីបន្ថែម សុទ្ធតែត្រូវបានទទួលការយល់ព្រមជាគោលការណ៍ពីរាជរដ្ឋាភិបាល។

ក្រៅពីនេះ អាជ្ញាធរសវនកម្មជាតិ បានជ្រើសរើសភ្នាក់ងារជាតិជាប់កិច្ចសន្យា ចំនួន៣៥នាក់បន្ថែមទៀត ដើម្បីបំពេញតម្រូវការជាក់ស្តែង។

#### ៧.១.២- កម្រិតវប្បធម៌

ក្រៅពីសវនករជាអតីតមន្ត្រីរាជការមានបទពិសោធន៍ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ សវនករផ្សេងទៀតជានិស្សិតបញ្ចប់ការសិក្សាផ្នែកគណនេយ្យគ្រប់គ្រងសេដ្ឋកិច្ច ច្បាប់ វិស្វករ ព័ត៌មានវិទ្យា។

ពិនិត្យជារួម កម្រិតវប្បធម៌របស់មន្ត្រីអាជ្ញាធរសវនកម្មជាតិ តាមសម្រង់តួលេខ ឆ្នាំ២០១១ នេះមានដូចខាងក្រោម ៖

- សញ្ញាបត្របណ្ឌិត ចំនួន ០២ នាក់
- សញ្ញាបត្រ គណនេយ្យសាធារណៈ CPA ចំនួន ០១ នាក់(ស្ត្រី)
- សញ្ញាបត្រ មន្ត្រីជាន់ខ្ពស់ ERA ចំនួន ០២ នាក់
- សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់កុំព្យូទ័រ ចំនួន ០២ នាក់
- សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់នយោបាយសង្គម ចំនួន ០១ នាក់
- សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ធុរៈកិច្ច ចំនួន ៨៦ នាក់(ស្ត្រី១៥)
- សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ច្បាប់ ចំនួន ០៦ នាក់(ស្ត្រី០២)
- សញ្ញាបត្រ បរិញ្ញាបត្រច្បាប់ ចំនួន ០២ នាក់(ស្ត្រី០១)
- សញ្ញាបត្រ បរិញ្ញាបត្រធុរៈកិច្ច ចំនួន ៨៦ នាក់(ស្ត្រី២៣)
- សញ្ញាបត្រ បរិញ្ញាបត្រព័ត៌មានវិទ្យា ចំនួន ០៥ នាក់
- សញ្ញាបត្រ កម្មករជំនាញបរិក្ខារត្រជាក់ ចំនួន ០១ នាក់។

### ៧.១.៣- ការលើកទឹកចិត្ត

ការលើកទឹកចិត្ត គឺជាយុទ្ធសាស្ត្រមួយដ៏សំខាន់នៃការគ្រប់គ្រងមន្ត្រីរាជការក្នុងការជំរុញកិច្ចប្រតិបត្តិការឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។ ក្នុងរយៈកាលកន្លងមក ការលើកទឹកចិត្តមានបីរូបភាព គឺ**ទីមួយ** ការផ្លាស់ប្តូរប្រភេទក្របខណ្ឌ និងការដំឡើងថ្នាក់ **ទីពីរ** ការផ្តល់គ្រឿងឥស្សរិយយស និង**ទីបី** គឺការចាត់បញ្ជូនមន្ត្រីឲ្យទៅសិក្សា ឬទៅធ្វើទស្សនកិច្ចសិក្សានៅបរទេស។ ក្នុងការអនុវត្តន៍គោលការណ៍លើកទឹកចិត្តនេះ អាជ្ញាធរសវនកម្មជាតិ ផ្តោតការយកចិត្តទុកដាក់ជាសំខាន់ដោយអនុលោមតាមនីតិវិធី នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការជាគោល និងច្បាប់ពាក់ព័ន្ធនានាដែលមានចែងពីការលើកទឹកចិត្តនេះ។



សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាបំពាក់គ្រឿងឥស្សរិយយស ជូនឯកឧត្តម **អ៊ិត ឈន** អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ



ឯកឧត្តម **ងួន ញ៉ិល** អនុប្រធានរដ្ឋសភា បំពាក់គ្រឿងឥស្សរិយយសជូនឯកឧត្តម **សេង រ៉ុន** អគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ



សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បំពាក់គ្រឿងឥស្សរិយយសជូនឯកឧត្តម **ឆាយ គឹម** អគ្គសវនករង នៃអាជ្ញាធរសវនកម្មជាតិ



ឯកឧត្តម **អ៊ុត ឈន** បំពាក់គ្រឿងឥស្សរិយយសជូនឯកឧត្តម **អ៊ុក សារាវុធ**



ឯកឧត្តម **អ៊ុំត ឈន** បំពាក់គ្រឿងឥស្សរិយយសជូនឯកឧត្តម **ប៉ា ហៀង**



ឯកឧត្តម **អ៊ុំត ឈន** បំពាក់គ្រឿងឥស្សរិយយសជូនលោកស្រី **គួយ ឡាង**

### ៧.១.៤- ការពង្រឹងសមត្ថភាពស្ថាប័ន

ទន្ទឹមនឹងការខិតខំបំពេញតួនាទីសវនកម្មផ្ទៃក្រៅទទួលបានលទ្ធផលល្អប្រសើរ ថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ នៅមានគោលបំណងសំខាន់បំផុតមួយ គឺការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងនោះទាមទារឲ្យមន្ត្រីមានសមត្ថភាពវិជ្ជាជីវៈពេញលេញ ក្នុងទិសដៅបំពេញការងារចុះធ្វើសវនកម្មឲ្យដំណើរការបានសមស្របជាមួយកម្មវិធីអាទិភាព និងយុទ្ធសាស្ត្រកែទម្រង់លើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល។

ព្រមជាមួយនេះ អាជ្ញាធរសវនកម្មជាតិបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ ដើម្បីជាត្រីវិស័យក្នុងកិច្ចប្រតិបត្តិការឲ្យទទួលបានជោគជ័យថែមទៀត។ កត្តាទាំងនេះមានបំណងឲ្យអាជ្ញាធរសវនកម្មជាតិ ក្លាយជាស្ថាប័នសវនកម្មកំពូល ប្រកបដោយសមត្ថភាព និងមានប្រសិទ្ធភាព ព្រមទាំងមានការគាំទ្រពីសាធារណជន និងបង្កើនផលិតភាព នៃមុខងារសវនកម្មផ្ទៃក្រៅរបស់ព្រះរាជាណាចក្រកម្ពុជា ដូចមានបង្ហាញជូនក្នុង រូបភាពដូចខាងក្រោម៖



### ៧.២- ការគ្រប់គ្រងចំណូល ចំណាយថវិកា

តាមច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរសវនកម្មជាតិមានថវិកាដោយឡែករបស់ខ្លួនផ្តល់ដោយថវិកាជាតិ គឺអាជ្ញាធរសវនកម្មជាតិអនុវត្តកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិការដ្ឋ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋាននានា ដែលមានចែងពាក់ព័ន្ធការគ្រប់គ្រងថវិកា ដូចបណ្តាក្រសួង ស្ថាប័ននានា។ ជាមួយនេះ អាជ្ញាធរសវនកម្មជាតិបានអនុវត្តនូវការគ្រប់គ្រងថវិកាក្នុងស្មារតីសន្សំសំចៃ និងប្រកបដោយប្រសិទ្ធភាពស្របតាមលក្ខខណ្ឌបច្ចេកទេសហិរញ្ញវត្ថុ ដែលក្នុងនេះសូមលើកដោយសង្ខេបកិច្ចការសំខាន់ៗដូចជា៖

- បានបង្កើតក្រុមការងារសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា
- បានបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានបង្កើតក្រុមការងារគ្រប់គ្រងគំរោងជំនួយនានា
- បានបង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា(PEAC) និងអង្គភាពលទ្ធកម្ម (PU)
- បានបង្កើតរដ្ឋទេយ្យករបុរេប្រទាន និងភ្នាក់ងារបើកផ្តល់
- បានធ្វើផែនការយុទ្ធសាស្ត្រថវិកា និងធ្វើគំរោងចំណាយថវិកាប្រចាំឆ្នាំ
- បានធ្វើផែនការចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស-ឆមាស និងប្រចាំឆ្នាំ
- បានធ្វើរបាយការណ៍ចំណាយថវិកា និងរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បានធ្វើរបាយការណ៍សរុបទូទាត់ចំណាយថវិកាប្រចាំឆ្នាំ
- បានរៀបចំផែនការសកម្មភាពតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានធ្វើរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ....។

### ៧.៣- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

អាជ្ញាធរសវនកម្មជាតិបានរៀបចំកិច្ចការមួយចំនួនក្នុងស្មារតីធានារក្សាការពារ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតនៅក្រោមការគ្រប់គ្រង និងប្រើប្រាស់របស់ខ្លួនស្របតាមបទបញ្ជារបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តិនានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានខាងក្រោម៖

- បានបង្កើតគណៈកម្មការកណ្តាលធ្វើបញ្ជីសារពើភ័ណ្ឌ និងគណៈកម្មការធ្វើបញ្ជីសារពើភ័ណ្ឌ នៃអង្គភាពប្រើប្រាស់
- បានគ្រប់គ្រងការប្រើប្រាស់ចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ ចុះបញ្ជីសារពើភ័ណ្ឌ រៀបចំថែទាំ និងជួសជុលសម្ភារៈបរិក្ខារ

- បានធ្វើតារាងប្រៀបធៀបស្តីពីការកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗ និងធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋសម្រាប់រយៈពេល ៥ឆ្នាំម្តង។

**៨- ការត្រួតពិនិត្យឡើងវិញលើបច្ចេកទេសវនកម្មមកលើអាជ្ញាធរសវនកម្មជាតិ(Peer Review)**

តាមស្តង់ដារសវនកម្ម របស់អង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល (INTOSAI) តម្រូវឲ្យបណ្តាស្ថាប័នសវនកម្មកំពូល នៃបណ្តាប្រទេសជាសមាជិកនីមួយៗ ធ្វើការពង្រឹងសមត្ថភាពលើការងារសវនកម្មតាមរយៈការត្រួតពិនិត្យឡើងវិញលើបច្ចេកទេសពីស្ថាប័នសវនកម្មកំពូលនៃបណ្តាប្រទេសណាមួយតាមការព្រមព្រៀងគ្នា។ ជាមួយនេះ អាជ្ញាធរសវនកម្មជាតិ តែងតែគិតគូរអំពីគុណភាពសវនកម្ម តាមរយៈការវាស់វែង និងវាយតម្លៃពីស្ថាប័នសវនកម្មកំពូល ដែលជាសមាជិកអង្គការ INTOSAI ។

ពាក់ព័ន្ធនឹងកិច្ចការនេះ អាជ្ញាធរសវនកម្មជាតិបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នសវនកម្មកំពូល នៃប្រទេសណូវែលហ្សេឡង់ តាមរយៈដំណើរទស្សនកិច្ចជាផ្លូវការទៅកាន់ប្រទេសណូវែលហ្សេឡង់របស់ឯកឧត្តម **អ៊ុត ឈន** នាឆ្នាំ២០០៩ ក្រោមការឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ គោលបំណង នៃការត្រួវពិនិត្យឡើងវិញលើបច្ចេកទេសនេះ ដើម្បីផ្តល់អនុសាសន៍ដល់អាជ្ញាធរសវនកម្មជាតិ ក្នុងការអភិវឌ្ឍន៍តួនាទីរបស់ខ្លួនឲ្យសមស្របក្នុងបរិស្ថានការងារសវនកម្មសាធារណៈ។

ការត្រួតពិនិត្យឡើងវិញលើបច្ចេកទេសនេះ សវនករ នៃស្ថាប័នសវនកម្មកំពូលប្រទេសញូវហ្សេឡែន ផ្តោតសំខាន់ទៅលើការរៀបចំស្ថាប័ន កិច្ចសហប្រតិបត្តិការ និងការកសាងសមត្ថភាព ដោយធ្វើការប្រៀបធៀបជាមួយការអនុវត្តន៍ល្អ និងស្តង់ដារអន្តរជាតិ។

ជាលទ្ធផល អាជ្ញាធរសវនកម្មជាតិទទួលបានអនុសាសន៍ល្អៗជាច្រើន ដើម្បីបំពេញចំណុចខ្វះខាត និងអភិវឌ្ឍន៍ខ្លួនឲ្យកាន់តែល្អថែមទៀត ពិសេសទាក់ទងដល់ការកសាងសមត្ថភាពធនធានមនុស្ស ដោយអាជ្ញាធរសវនកម្មជាតិបញ្ចូលចំណុចសំខាន់ៗ ទាំងនោះក្នុងផែនយុទ្ធសាស្ត្រការអភិវឌ្ឍន៍ ២០១២-២០១៦។

## II- លទ្ធផលការងារសវនកម្ម

អាជ្ញាធរសវនកម្មជាតិ ចាប់ផ្តើមកិច្ចប្រតិបត្តិការការងារបច្ចេកទេសសវនកម្ម នៅដើមឆ្នាំ ២០០២ ដោយបានខិតខំបំពេញតួនាទី និងភារកិច្ចយ៉ាងសកម្មស្របតាមផែនការគ្រោងទុកប្រចាំឆ្នាំ។ នៅរៀងរាល់ឆ្នាំ ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាមូលដ្ឋាន និងផែនការប្រចាំឆ្នាំ អាជ្ញាធរសវនកម្មជាតិ សម្រេចបានលទ្ធផលការងារសវនកម្មគួរឲ្យកត់សំគាល់ ដូចតទៅ៖

**១- សកម្មភាពចុះធ្វើសវនកម្ម** (**២០០២-២០១១**)

ក្នុងការអនុវត្តការងារកន្លងមក អាជ្ញាធរសវនកម្មជាតិជួបការប្រឈមយ៉ាងច្រើនដោយសារការចាប់ផ្តើមដំបូង ជាពិសេសកង្វះខាតធនធានមនុស្ស និងសម្ភារៈបរិក្ខារបច្ចេកទេសសម្រាប់ជួយដល់ការងារសវនកម្មឲ្យបានសមស្របៗល។ ប៉ុន្តែទោះជាយ៉ាងណាក្តី អាជ្ញាធរសវនកម្មជាតិបានខិតខំជំនះគ្រប់ឧបសគ្គក្នុងការធ្វើសវនកម្មកន្លងមកតាមប្រភេទ៖

- សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
- សវនកម្មលើការអនុលោមតាមច្បាប់
- សវនកម្មលើកិច្ចប្រតិបត្តិការ(ទើបសាកល្បង)។

ទន្ទឹមនេះ អាជ្ញាធរសវនកម្មជាតិ បាននិង កំពុងធ្វើសវនកម្មសាកល្បងដោយប្រើប្រាស់ព័ត៌មានវិទ្យាតាមកម្មវិធីTeamMate ដូចបណ្តាប្រទេសមួយចំនួន។ ការប្រើប្រាស់កម្មវិធីនេះ ជួយដល់សវនករអនុវត្តការងារសវនកម្មទទួលបានប្រសិទ្ធភាព និងទាន់ពេលវេលា។

ផ្អែកលើវិធីសាស្រ្តការងារជាមូលដ្ឋានដូចខាងលើ ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ អាជ្ញាធរសវនកម្មជាតិបានខិតខំកែទម្រង់ការអនុវត្តន៍ការងារសវនកម្មជាបណ្តើរៗ ដោយអនុលោមទៅតាមស្តង់ដារសវនកម្ម។

ចាប់តាំងពីធ្វើសវនកម្មដំបូងនៅឆ្នាំ២០០២ ដល់ឆ្នាំ២០១១នេះ អាជ្ញាធរសវនកម្មជាតិបានខិតខំអនុវត្តយ៉ាងខ្ជាប់ខ្ជួន ដោយទទួលបានលទ្ធផលសម្រេចជារបាយការណ៍សវនកម្ម សរុបចំនួន **៦៩៥ករណី** ដូចមានបង្ហាញតាមមុខសញ្ញាសវនកម្ម ក្នុងតារាងទី១ និងទី២ ខាងក្រោម៖

**តារាងទី១៖ សេចក្តីសង្ខេបចំនួនសវនកម្មដែលអនុវត្តបានចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០១១**

| ល.រ | ឆ្នាំ / មុខសញ្ញាសវនកម្ម | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | សរុប១០ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកា | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | **១០** |
| ២ | ក្រសួង ស្ថាប័ន | - | ៣ | ៤ | ៩ | ៤ | ១០ | ៧ | ៩ | ៨ | ១៧ | **៧១** |
| ៣ | អាជ្ញាធរ និងធនាគារ | - | ១ | ១ | ១ | ១ | ២ | ២ | ៣ | ២ | ៣ | **១៦** |
| ៤ | សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ | ១ | | ១ | ១ | ២ | ៣ | ៥ | ៥ | ៥ | ៧ | **៣០** |
| ៥ | ខេត្ត-ក្រុង | - | | ២ | ៣ | ២ | ៦ | ៩ | ៩ | ១០ | ១៣ | **៥៤** |
| ៦ | ឃុំ-សង្កាត់នានាតាម បណ្តាខេត្ត-ក្រុង | - | | ១៦១ | - | ៣៥ | ៤២ | ២៦ | ៤៨ | ៤៨ | ៤៨ | **៤០៨** |
| ៧ | កិច្ចសន្យាផ្គត់ផ្គង់ របស់ក្រុមហ៊ុន | - | | | ១ | - | ៣ | ៣ | ៣ | ៤ | ១២ | **២៦** |
| ៨ | កិច្ចសន្យាសម្បទាន (វិនិយោគ) | - | | | ១ | ២ | ៣ | ៣ | ២ | ២ | ២ | **១៥** |
| ៩ | គម្រោងរបស់ ដៃគូអភិវឌ្ឍន៍ | - | | | - | ៣ | ៣ | ២ | ១ | ២ | - | **១១** |
| ១០ | សវនកម្មសំណើពិសេស | - | | | - | - | ២ | - | ១ | - | ១ | **៤** |
| | សរុប | **២** | **៥** | **១៧០** | **១៧** | **៥០** | **៧៥** | **៥៨** | **៨២** | **៨២** | **១០៤** | **៦៩៥** |

## តារាងទី២៖ លទ្ធផលនៃកិច្ចប្រតិបត្តិការតាមបណ្តាអង្គភាពរងសវនកម្ម (២០០២-២០១១)

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| **ឆ្នាំ២០០២** | | <u>០២</u> | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ ២០០១ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | សហគ្រាសសាធារណៈ | ០១ | ក្រុមហ៊ុននាវាជំនួញសមុទ្រកម្ពុជា |
| **ឆ្នាំ២០០៣** | | <u>០៥</u> | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០០២ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង | ០៣ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់អាជ្ញាធរ | ០១ | - អាជ្ញាធរអគ្គិសនីកម្ពុជា |
| **ឆ្នាំ២០០៤** | | <u>១៧០</u> | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០០៣ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង | ០៤ | - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់អាជ្ញាធរ | ០១ | អាជ្ញាធរអគ្គិសនីកម្ពុជា |
| ៤ | សហគ្រាសសាធារណៈ | ០១ | - រដ្ឋាករទឹកស្វយ័តភ្នំពេញ |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ០២ | - សាលាក្រុងព្រះសីហនុ<br>- សាលាខេត្តបាត់ដំបង |
| ៦ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ១៦១ | - ឃុំ-សង្កាត់នានាតាមបណ្តាខេត្ត-ក្រុង |
| **ឆ្នាំ២០០៥** | | <u>១៧</u> | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០០៤ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច- | ០៩ | - ក្រសួងពាណិជ្ជកម្ម |

| | | | |
|---|---|---|---|
| | ប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន | | - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងកិច្ចការនារី (ធ្វើសវនកម្មលើលទ្ធកម្ម)<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ(ធ្វើសវនកម្មលើទ្រព្យសម្បត្តិរដ្ឋ)<br>- ក្រសួងទេសចរណ៍(ធ្វើសវនកម្មលើទ្រព្យសម្បត្តិរដ្ឋ)<br>- ក្រសួងព័ត៌មាន(ធ្វើសវនកម្មលើទ្រព្យសម្បត្តិរដ្ឋ)<br>- គណៈកម្មការជាតិរៀបចំការបោះឆ្នោត |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់អាជ្ញាធរ | ០១ | - អាជ្ញាធរអគ្គិសនីកម្ពុជា |
| ៤ | សហគ្រាសសាធារណៈ | ០១ | - កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ០៣ | - សាលាក្រុងភ្នំពេញ<br>- សាលាខេត្តសៀមរាប<br>- សាលាខេត្តព្រៃវែង(ធ្វើសវនកម្មលើលទ្ធកម្ម) |
| ៦ | គំរោងរបស់ដៃគូអភិវឌ្ឍន៍ | ០១ | - គំរោងស្តារឡើងវិញនូវផ្លូវជាតិជាអាទិភាព លេខ1697-CAM(SF) នៅក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៧ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០១ | - កិច្ចសន្យាសម្បទាននៅក្រុមហ៊ុន Société Concessionnaire de l'Aéroport(SCA) |
| **ឆ្នាំ២០០៦** | | **<u>៥០</u>** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០០៥ | ០១ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង | ០៤ | - ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | | | |
|---|---|---|---|
| | | | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់អាជ្ញាធរ | ០១ | - អាជ្ញាធរអគ្គិសនីកម្ពុជា |
| ៤ | សហគ្រាសសាធារណៈ | ០២ | - កំពង់ផែស្វយ័តក្រុងភ្នំពេញ<br>- អគ្គិសនីកម្ពុជា |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ០២ | - សាលាខេត្តស្វាយរៀង<br>- សាលាខេត្តកណ្ដាល |
| ៦ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ៣៥ | - ឃុំ នៃខេត្តកំពង់ស្ពឺចំនួន០៩<br>- ឃុំ នៃខេត្តកំពតចំនួន០៩<br>- ឃុំ នៃខេត្តកំពង់ឆ្នាំងចំនួន០៧<br>- ឃុំ នៃខេត្តបាត់ដំបងចំនួន១០ |
| ៧ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០២ | - កិច្ចសន្យាសម្បទានផ្លូវជាតិលេខ ៤ នៅក្រុមហ៊ុន AZ Distribution Co., Ltd.<br>- កិច្ចសន្យាសម្បទាននៅក្រុមហ៊ុនកាំមីនតែលក្រុមហ៊ុន ម៉ូប៊ីតែល និងក្រុមហ៊ុន ខាំស៊ីន |
| ៨ | កិច្ចសន្យាផ្គត់ផ្គង់របស់ក្រុមហ៊ុន | ០៣ | - ក្រុមហ៊ុន ងួន វុទ្ធី ត្រេឌីង ឌីវើឡុបមែន ខបផូរ៉េហ្សិន<br>- ក្រុមហ៊ុន ណារី ហ្គាមេន អេនត្រេឌីង គ្រុប<br>- ក្រុមហ៊ុន សោម សុផល ជាមួយក្រសួងនានា |
| **ឆ្នាំ២០០៧** | | **៧៥** | |
| ១ | សេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាឆ្នាំ២០០៦ | ០១ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន | ១០ | - ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- ក្រសួងសុខាភិបាល<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ច- | ០២ | - អាជ្ញាធរអគ្គិសនីកម្ពុជា |

| | | | |
|---|---|---|---|
| | ប្រតិបត្តិការរបស់អាជ្ញាធរ | | - អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៣ | - សាកលវិទ្យាល័យភូមិន្ទកសិកម្ម<br>- ចំការកៅស៊ូជប់<br>- ចំការកៅស៊ូពាមជាំង |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ០៦ | - សាលាខេត្តព្រៃវែង<br>- សាលាខេត្តកំពត<br>- សាលាខេត្តក្រចេះ<br>- សាលាខេត្តបន្ទាយមានជ័យ<br>- សាលាខេត្តតាកែវ<br>- សាលាខេត្តកំពង់ធំ |
| ៦ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ៤២ | - ឃុំ នៃខេត្តព្រៃវែង ចំនួន ១២<br>- ឃុំ នៃខេត្តកំពត ចំនួន ០៩<br>- ឃុំ នៃខេត្តក្រចេះ ចំនួន ០៥<br>- ឃុំ នៃខេត្តតាកែវ ចំនួន ១០<br>- ឃុំ នៃខេត្តបន្ទាយមានជ័យ ចំនួន ០៦ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០៣ | - គម្រោងអភិវឌ្ឍន៍វិស័យអប់រំ ក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងលេខ 1865-CAM(SF)<br>- គម្រោងគាំទ្រវិស័យសុខាភិបាល លេខ IDA 3728-KH នៅក្រសួងសុខាភិបាល<br>- គម្រោងអភិវឌ្ឍន៍វិស័យកសិកម្មលេខ 2023-CAM |
| ៨ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០៣ | - រវាងក្រុមហ៊ុន ខូធីប្រ៊ីសប់ ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- រវាងក្រុមហ៊ុន សុខាអូតែល ជាមួយអាជ្ញាធរអប្សរា<br>- និងកិច្ចសន្យាសម្បទានអាជីវកម្មថ្មក្រានីត ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅខេត្តក្រចេះ |
| ៩ | កិច្ចសន្យាផ្គត់ផ្គង់របស់ក្រុមហ៊ុន | ០៣ | ជាមួយក្រសួង:<br>- អភិវឌ្ឍន៍ជនបទ<br>- សាធារណការ និងដឹកជញ្ជូន<br>- យុត្តិធម៌ |

| | | | |
|---|---|---|---|
| ១០ | សវនកម្មតាមសំណើពិសេស | ០២ | - ការងារអាជីវកម្មរបស់ក្រុមហ៊ុន ទូរគមនាគមន៍ ក្នុងរយៈពេល ៥ ឆ្នាំ<br>- របាយការណ៍ហិរញ្ញវត្ថុ នៃគម្រោងជំនួយ របស់កម្មវិធីបរិស្ថានសហប្រជាជាតិនៅ ក្រសួងបរិស្ថាន |
| **ឆ្នាំ២០០៨** | | <u>៥៨</u> | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០០៧ | ០១ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាព ក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន | ០៧ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងយុត្តិធម៌<br>- ក្រសួងព័ត៌មាន<br>- និងគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ចប្រ-តិបត្តិការរបស់អាជ្ញាធរនិងធនាគារ | ០២ | - ធនាគារជាតិ<br>- អាជ្ញាធរអគ្គិសនីកម្ពុជា |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាស សាធារណៈ | ០៥ | - រាជាយស្ម័យយានកម្ពុជា<br>- សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>- សាកលវិទ្យាល័យសុខាភិបាល<br>-វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា<br>- រដ្ឋាករទឹកស្វយ័តភ្នំពេញ |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ០៩ | - សាលាក្រុងព្រះសីហនុ<br>- សាលាក្រុងប៉ៃលិន<br>- សាលាខេត្តបាត់ដំបង<br>- សាលាខេត្តបន្ទាយមានជ័យ<br>- សាលាខេត្តកោះកុង<br>- សាលាខេត្តកំពង់ឆ្នាំង<br>- សាលាខេត្តពោធិ៍សាត់<br>- សាលាខេត្តស្ទឹងត្រែង<br>- សាលាខេត្តកំពង់ស្ពឺ |
| ៦ | ចំណូល ចំណាយថវិកា និងកិច្ច- | ២៦ | - ឃុំ នៃខេត្តបាត់ដំបង ចំនួន ១០ |

| | | | |
|---|---|---|---|
| | ប្រតិបត្តិការរបស់ឃុំ-សង្កាត់ | | - ឃុំ នៃខេត្តពោធិ៍សាត់ ចំនួន ០៦<br>- ឃុំ នៃខេត្តកោះកុង ចំនួន ០៥<br>- សង្កាត់នៃខេត្តព្រះសីហនុ ចំនួន ០៥ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០៣ | - គម្រោងអភិវឌ្ឍន៍វិស័យទេសចរមេគង្គ ក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លេខ 1969-CAM(SF)<br>- គម្រោងអគ្គិសនីជនបទ និងខ្សែបញ្ជូន ក្រោមឥណទានធនាគារពិភពលោក លេខ 3840-KH<br>- គម្រោងអភិវឌ្ឍន៍វិស័យអប់រំ ក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ីលេខ 2122-CAM(SF) |
| ៨ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ០៣ | - កិច្ចសន្យាសម្បទានវិនិយោគលើការដាំដើមម៉ៃសាក់ និងការកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន Green Sea<br>- កិច្ចសន្យាសម្បទានរវាងសាលាខេត្តបន្ទាយមានជ័យ និងក្រុមហ៊ុនបាណន់<br>- កិច្ចសន្យាសម្បទានរវាងសាលាខេត្តមណ្ឌលគិរី ជាមួយក្រុមហ៊ុន សឡាអ៊ិនវេសមិន |
| ៩ | កិច្ចសន្យាផ្គត់ផ្គង់របស់ក្រុមហ៊ុន | ០២ | ជាមួយក្រសួង:<br>- ការពារជាតិ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី |
| **ឆ្នាំ ២០០៩** | | <u>៨២</u> | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០០៨ | ០១ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន | ០៩ | - ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងធម្មការ និងសាសនា<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ |

| | | | |
|---|---|---|---|
| | | | - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់អាជ្ញាធរ និងធនាគារ | ០៣ | - ធនាគារអភិវឌ្ឍន៍អាស៊ី<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អាជ្ញាធរគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៥ | - កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>- កំពង់ផែស្វយ័តក្រុងភ្នំពេញ<br>- រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប<br>- ក្រុមហ៊ុនកម្ពុជានាវាចរណ៍ (កាំសាប)<br>- មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ០៩ | - សាលាខេត្តសៀមរាប<br>- សាលាខេត្តព្រៃវែង<br>- សាលាខេត្តស្វាយរៀង<br>- សាលាខេត្តកណ្តាល<br>- សាលាខេត្តកំពត<br>- សាលាខេត្តកំពង់ចាម<br>- សាលាខេត្តរតនគិរី<br>- សាលាខេត្តកែប<br>- សាលាខេត្តមណ្ឌលគិរី |
| ៦ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ៤៨ | - ឃុំ នៃខេត្តស្វាយរៀង ចំនួន ១២<br>- ឃុំ នៃខេត្តសៀមរាប ចំនួន ១២<br>- ឃុំ នៃខេត្តកណ្តាល ចំនួន ១២<br>- ឃុំ នៃខេត្តព្រៃវែង ចំនួន ១២ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០៣ | - គម្រោងកែលម្អអាកាសយានដ្ឋានខេត្តរតនគិរី នៃគម្រោងអភិវឌ្ឍន៍វិស័យទេសចរណ៍មេគង្គ លេខ 1969-CAM(SF)<br>- គម្រោងគ្រប់គ្រងបឹងទន្លេសាប លេខ 1939-CAM(SF)<br>- គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ និងទីរួមខេត្ត លេខ 3822-CAM(SF) (នៅក្រសួងសាធារណការ និងដឹកជញ្ជូន និង នៅក្រសួងអភិវឌ្ឍន៍ជនបទ) |
| ៨ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០២ | - កិច្ចព្រមព្រៀងវិនិយោគរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុនអភិវឌ្ឍន៍រតនវិសាល |

| | | | |
|---|---|---|---|
| | | | - កិច្ចសន្យាវិនិយោគស្តីពីការធ្វើផ្លូវថោមថៅ-ស្ទឹងមានជ័យ |
| ៩ | កិច្ចសន្យាផ្គត់ផ្គង់របស់ក្រុមហ៊ុន | ០១ | - កិច្ចសន្យាផ្គត់ផ្គង់ទំនិញមៅការសេវាកម្មផ្សេងៗនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| ១០ | សវនកម្មតាមសំណើពិសេសស | ០១ | គម្រោងអភិវឌ្ឍន៍វិស័យអប់រំ ក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ីលេខ2122-CAM(SF) |
| **ឆ្នាំ ២០១០** | | <u>៨២</u> | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០០៩ | ០១ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន | ០៨ | - ក្រសួងធនធានទឹក និងឧតុនិយម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់អាជ្ញាធរ | ០២ | - អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អាជ្ញាធរអប្សរា |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៥ | - ទូរគមនាគមន៍កម្ពុជា<br>- កំពង់ផែស្វយ័តក្រុងភ្នំពេញ<br>- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>- អគ្គិសនីកម្ពុជា<br>- វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កសិកម្ម |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ១០ | - សាលាខេត្តកោះកុង<br>- សាលាខេត្តក្រចេះ<br>- សាលាខេត្តឧត្តរមានជ័យ<br>- សាលាខេត្តកំពង់ឆ្នាំង<br>- សាលាខេត្តបន្ទាយមានជ័យ<br>- សាលាខេត្តកំពង់ធំ<br>- សាលាខេត្តមណ្ឌលគិរី<br>- សាលាខេត្តកំពង់ស្ពឺ<br>- សាលារាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| | | | - សាលាក្រុងព្រះសីហនុ |
| ៦ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ៤៨ | - ឃុំ នៃខេត្តកោះកុង ចំនួន ១២<br>- ឃុំ នៃខេត្តកំពង់ឆ្នាំង ចំនួន ១២<br>- ឃុំ នៃខេត្តបន្ទាយមានជ័យ ចំនួន ១២<br>- សង្កាត់ នៃរាជធានីភ្នំពេញ ចំនួន ១២ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០៤ | - គម្រោងទ្រទ្រង់វិស័យសុខាភិបាល លេខ 1940-CAM(SF) នៅក្រសួងសុខាភិបាល<br>- គម្រោងវិស័យធារាសាស្ត្រទិសពាយព្យ លេខ 2035-CAM(SF) នៅក្រសួងធនធានទឹក និងឧតុនិយម<br>- គម្រោងវិនិយោគជនបទ និងអភិវឌ្ឍន៍ក្នុងតំបន់លេខ IDA-3260-KH នៅក្រសួងអភិវឌ្ឍន៍ជនបទ<br>- និងគម្រោងពង្រីកកំពង់ផែស្វយ័តក្រុងព្រះសីហនុបន្ទាន់ ក្រោមប្រាក់កម្ចីប្រទេសជប៉ុន |
| ៨ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០២ | - កិច្ចសន្យាសម្បទានរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាមួយបណ្តាក្រុមហ៊ុនវិនិយោគថ្មកំបោរ នៅខេត្តកំពត<br>- កិច្ចសន្យាសម្បទាន ស្តីពីការសំអាត ប្រមូល និងដឹកជញ្ជូនសំណល់/សំរាមទៅចោលនៅជាយក្រុង ជាមួយសាលារាជធានីភ្នំពេញ ជាមួយក្រុមហ៊ុន CINTRI (CAMBODIA)LTD |
| ៩ | កិច្ចសន្យាផ្គត់ផ្គង់របស់ក្រុមហ៊ុន | ០២ | សវនកម្មលើកិច្ចសន្យា ស្តីពី:<br>- កិច្ចសន្យាផ្គត់ផ្គង់ទំនិញ មៅការសេវាកម្មផ្សេងៗរបស់ក្រសួងសុខាភិបាល និងមន្ទីរមួយចំនួនក្រោឱវាទ<br>- កិច្ចសន្យាផ្គត់ផ្គង់ទំនិញ មៅការសេវាកម្មផ្សេងៗរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| **ឆ្នាំ ២០១១** | | **១០៤** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ២០១០ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |

| | | | |
|---|---|---|---|
| ២ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន | ១៧ | - ក្រសួងយុត្តិធម៌<br>- ក្រសួងសុខាភិបាល<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងផែនការ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ៣ | ចំណូល ចំណាយថវិកា និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរ និងធនាគារ | ០៣ | - អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍<br>- ធនាគារអភិវឌ្ឍន៍ជនបទ |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៧ | - កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>- រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប<br>- មន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត<br>- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច<br>- កំពង់ផែស្វយ័តក្រុងភ្នំពេញ<br>- សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៥ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ខេត្ត-ក្រុង | ១៣ | - សាលាខេត្តកំពង់ចាម<br>- សាលាខេត្តរតនគិរី<br>- សាលាខេត្តកណ្តាល<br>- សាលាខេត្តព្រៃវែង |

| | | | |
|---|---|---|---|
| | | | - សាលាខេត្តស្វាយរៀង<br>- សាលាខេត្តកែប<br>- សាលាខេត្តកំពត<br>- សាលាខេត្តពោធិ៍សាត់<br>- សាលាខេត្តស្ទឹងត្រែង<br>- សាលាខេត្តបាត់ដំបង<br>- សាលាខេត្តប៉ៃលិន<br>- សាលាខេត្តព្រះវិហារ<br>- សាលាខេត្តតាកែវ |
| ៦ | ចំណូល ចំណាយថវិកា និងកិច្ច-ប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ៤៨ | - ឃុំ នៃខេត្តកំពត ចំនួន ១២ឃុំ<br>- ឃុំ នៃខេត្តបាត់ដំបង ចំនួន ១២ឃុំ<br>- ឃុំ នៃខេត្តព្រៃវែង ចំនួន ១២ឃុំ<br>- ឃុំ នៃខេត្តស្ទឹងត្រែង ចំនួន ១២ឃុំ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ១២ | - គម្រោងកែលម្អ និងការគ្រប់គ្រង ថែទាំផ្លូវ លេខ 1945-CAM(SF) របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងលេខ IDA-44420 របស់ធនាគារពិភពលោក នៅក្រសួងសាធារណ-ការនិង ដឹកជញ្ជូន<br>- គម្រោងគាំទ្រវិស័យសុខាភិបាល ជំហានទី ២ លេខTF093574 និងលេខ IDA 44700 របស់ធនាគារពិភពលោកនៅក្រសួងសុខាភិបាល<br>- គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សហគមន៍ខ្នាតតូចនៅតំបន់ទន្លេសាបលេខ 186-CAM(SF) របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ<br>- គម្រោងជំនួយស្បៀងអាហារសង្គ្រោះបន្ទាន់ លេខ 0116-CAM(SF) និងលេខ 2455-CAM(SF)របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គម្រោងវិស័យផ្គត់ផ្គង់ទឹកស្អាតតាមជនបទ ជំហានទី ២ លេខ 156-CAM(SF) របស់ |

| | | | |
|---|---|---|---|
| | | | ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្រសួងអភិវឌ្ឍន៍ជនបទ<br>- គម្រោងខ្សែអគ្គិសនីជនបទ លេខ IDA 3840 របស់ធនាគារពិភពលោក នៅអគ្គិសនីកម្ពុជា<br>- គម្រោងដោះស្រាយផលប៉ះពាល់គោលនយោបាយពាក់ព័ន្ធនឹងផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គម្រោងដោះស្រាយជីផ្លីសម្រាប់វិស័យសង្គមកិច្ច និងអភិវឌ្ឍន៍សេដ្ឋកិច្ចលេខ IDA-H3860 របស់ធនាគារពិភពលោក នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- គម្រោងគាំទ្រវិស័យអប់រំលេខ IDA-H0161 របស់ក្រសួងអប់រំ យុវជន និងកីឡា និងគម្រោងជំរុញគុណភាពអប់រំលេខ 90 របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្រសួងអប់រំ យុវជន និងកីឡា |
| ៨ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០២ | - កិច្ចព្រមព្រៀងវិនិយោគ រ៉ែ ត្បូង និងថ្ម រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាមួយក្រុមហ៊ុន Jirech International Cambodia Construction and Import Export Co., Ltd.<br>- កិច្ចសន្យាសម្បទានវិនិយោគផ្លូវលេខ 2004 និងផ្លូវលេខ 371 រវាងសាលារាជធានីភ្នំពេញ ជាមួយក្រុមហ៊ុន សុខឡា អ៊ិនវេសមេន |
| ៩ | សវនកម្មតាមសំណើពិសេស | ០១ | គម្រោងគាំទ្រវិស័យអប់រំសម្រាប់ឆ្នាំ2008-2010 តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា |

លើសពីនេះ អាជ្ញាធរសវនកម្មជាតិ បានធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលសវនកម្ម សម្រាប់ការិយបរិច្ឆេទ២០០៦ និង២០០៧ ព្រមទាំងត្រៀមរៀបចំការផ្សព្វផ្សាយរបាយការណ៍ជាសាធារណៈសម្រាប់ការិយបរិច្ឆេទ២០០៨ និង២០០៩ នាពេលខាងមុខ។

**២- ការកែលម្អតាមអនុសាសន៍សវនកម្ម**

កន្លងមកអង្គភាពរងសវនកម្មនានា ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយកចិត្តទុកដាក់ និងខិតខំអនុវត្តកែលំអតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិដែលបានលើកឡើងជាបន្តបន្ទាប់ មានជាអាទិ៍៖

- ការលុបបំបាត់ជាបន្តបន្ទាប់នូវរបបគយនាំចូលដើម្បីនាំចេញដែលគ្រប់គ្រងមិនបាន
- ការផ្លាស់ប្តូរពីការបង់ពន្ធជាសាច់ប្រាក់នៅនឹងកន្លែង មកការបង់ពន្ធតាមរយៈធនាគារ ឬរតនាគារដើម្បីកាត់បន្ថយហានិភ័យក្នុងការគ្រប់គ្រងសាច់ប្រាក់
- ការផ្លាស់ប្តូរលេខអត្តសញ្ញាណកម្មសារពើពន្ធថ្មី ដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មក្រុមហ៊ុន- សហគ្រាសឲ្យមានប្រសិទ្ធភាព
- ការណែនាំជំរុញឲ្យមានបង់ពន្ធប្រថាប់ត្រាលើគ្រប់កិច្ចសន្យាផ្គត់ផ្គង់ទំនិញជូនរដ្ឋ
- ការចេញសេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗ ស្តីពីការទារបំណុលសារពើពន្ធ និងមិនមែនសារពើពន្ធជាច្រើនករណី។
- ការធ្វើឲ្យមានភាពប្រសើរក្នុងការបើកផ្តល់សាច់ប្រាក់ និងការពង្រឹងកិច្ចលទ្ធកម្មសាធារណៈ
- ការណែនាំជំរុញឲ្យធ្វើបញ្ជីសារពើភ័ណ្ឌ និងបណ្ណសំគាល់កម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ
- ការផ្លាស់ប្តូរកិច្ចបញ្ជិកាគណនេយ្យពីការប្រើប្រាស់មូលដ្ឋានសាច់ប្រាក់ផង និងបង្គរផង មកប្រើប្រាស់តែមូលដ្ឋានតែមួយ និងការកាន់បញ្ជិកាបំណុលប្រមូលផ្តុំនៅរតនាគារជាតិជាដើម។

ប៉ុន្តែទន្ទឹមនឹងនោះ ក៏មានចំណុចមួយចំនួនពុំទាន់ត្រូវបានធ្វើការអនុវត្តកែលម្អនៅឡើយដូចនេះ ចំពោះមុខ ក្នុងគោលដៅដើម្បីជួយជំរុញការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យមានភាពកាន់តែល្អប្រសើរ និងរឹងមាំថែមទៀត អាជ្ញាធរសវនម្មជាតិសូមស្នើដល់គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងឡាយ បន្តខិតខំគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយអនុវត្តតាមតួនាទីភារកិច្ចរបស់ខ្លួន និងយកចិត្តទុកដាក់កែលម្អតាមអនុសាសន៍សវនកម្ម ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង។ ក្នុងពេលនេះ ខ្ញុំសូមលើកនូវអនុសាសន៍មួយចំនួន រួមមានដូចជា៖

- ចំពោះចំណូល ត្រូវពង្រឹងបន្ថែមទៀតក្នុងការអនុវត្តន៍ប្រមូលចំណូលគ្រប់ប្រភេទបំណុលនិងអនុវត្តវិន័យបង់ចំណូលចូលថវិការដ្ឋឲ្យបានសមស្របតាមបទប្បញ្ញត្តិច្បាប់ លើសពីនេះទៀត គឺការទប់ស្កាត់ និងការបង្ក្រាបការគេចវេះពន្ធឲ្យមានប្រសិទ្ធភាព

- ចំណែកការចំណាយថវិកាត្រូវប្រកាន់ខ្ជាប់នូវនីតិវិធីហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មសាធារណៈឲ្យបានម៉ឺងម៉ាត់
- ចំណូល-ចំណាយដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ត្រូវពង្រឹងយន្តការគ្រប់គ្រងឲ្យហ្មត់ចត់ ពិសេសអំពីការកត់ត្រាអំណោយបរទេស
- បំណុលគ្រប់ប្រភេទត្រូវមានកិច្ចបញ្ជិកាប្រមូលផ្តុំច្បាស់លាស់ ដើម្បីមានភាពងាយស្រួលក្នុងការត្រួតពិនិត្យ តាមដាន និងចាត់វិធានការតឹងទារបានទាន់ពេលវេលា
- ទ្រព្យសម្បត្តិរដ្ឋ ត្រូវពង្រឹងការគ្រប់គ្រងឲ្យបានម៉ឺងម៉ាត់ ដោយធ្វើការជំរុញការធ្វើបណ្ណសម្គាល់កម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋឲ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

# ផ្នែកទី ៣
# សេចក្តីសន្និដ្ឋាន

១០ឆ្នាំកន្លងមកនេះ គឺជាដំណាក់កាលដំបូង និងជាប្រវត្តិសាស្ត្រ នៃការស្ថាបនាអាជ្ញាធរសវនកម្មជាតិ ដែលយើងទាំងអស់គ្នា បានខិតខំពូតដៃគ្នាកសាងស្ថាប័នសវនកម្មកំពូលមួយនេះ ពីបាតដៃទទេរហូតទទួលបានជោគជ័យដល់បច្ចុប្បន្ន ព្រមទាំងបានចូលរួមចំណែកក្នុងការផ្តល់ជាអនុសាសន៍ល្អៗ ក្នុងរបាយការណ៍លទ្ធផលសវនកម្ម ជូនដល់រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីមានមូលដ្ឋានក្នុងការពិនិត្យ និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រង និងទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំនីមួយៗ ជាពិសេសចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តន៍ឲ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដែលជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាណាចក្រកម្ពុជា។ ព្រមជាមួយគ្នានេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តកិច្ចខិតខំអនុវត្តការងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាលឲ្យទទួលបានលទ្ធផលល្អតាមការរំពឹងទុកប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។

សមិទ្ធិផលគួរឲ្យកត់សម្គាល់ក្នុងរយៈពេល ១០ឆ្នាំ កន្លងមកនេះ គឺយើងបានដាក់ចេញនូវៈ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០០៧-២០១១) ដែលជាត្រីវិស័យសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍន៍ស្ថាប័នសម្រេចបាននូវស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា សៀវភៅណែនាំ គោលការណែនាំ ចងក្រងឯកសារគតិយុត្តិ និងឯកសារសវនកម្មជាច្រើនទៀត។

ឯកសារគោលទាំងឡាយនេះ កើតចេញពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់អាជ្ញាធរសវនកម្មជាតិ ក្នុងទិសដៅពង្រឹងសមត្ថភាពអាជ្ញាធរសវនកម្មជាតិឲ្យរត់តាមចង្វាក់អភិវឌ្ឍន៍ប្រព័ន្ធសវនកម្មសាធារណៈសកល។ ជាមួយការរីកចម្រើនលើការងារសវនកម្មដែលជាកិច្ចការមូលដ្ឋាន អាជ្ញាធរសវនកម្មជាតិបានទទួលជោគជ័យលើការងារទំនាក់ទំនងអន្តរជាតិ ក្នុងនោះ អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិកអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(INTOSAI) និងអង្គការអាស៊ី នៃស្ថាប័នសវនកម្មកំពូល(ASOSAI) ព្រមទាំងចូលជាសមាជិកក្រុមការងារផ្សេងៗ នៅក្នុងអង្គការ INTOSAI ទៀតផង។ ជាមួយនេះ អាជ្ញាធរសវនកម្មជាតិបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយបណ្តាស្ថាប័នសវនកម្មកំពូលនានា ក្នុងគោលបំណងអភិវឌ្ឍន៍ស្ថាប័នឲ្យបានសមស្របតាមកម្រិតស្តង់ដារអន្តរជាតិ។

ទន្ទឹមនឹងភាពជោគជ័យនេះ អាជ្ញាធរសវនកម្មជាតិ ក៏ជួបប្រទះបញ្ហាប្រឈមជាច្រើន ព្រោះស្ថាប័នទើបតែកកើត ធនធានមនុស្សនៅមានកម្រិត ដោយការកសាងធនធានមនុស្សទាមទាររយៈពេលយូរ ខ្វះខាតបច្ចេកវិទ្យាព័ត៌មានវិទ្យា ទីកន្លែងតូចចង្អៀត ជាពិសេសមន្ត្រីដែលទទួលបានបទពិសោធន៍ល្អៗ សុំព្យួរការងារទៅបម្រើការងារក្នុងវិស័យឯកជន ដែលទទួលបានកំរៃច្រើន។ល។

ទោះបីជាជួបការលំបាកដូចនេះក្តី យើងបានកំណត់ច្បាស់លាស់នូវមូលហេតុទាំងឡាយ

និងសង្ឃឹមថា នឹងជំនះបាននូវរាល់ឧបសគ្គទាំងនេះនាពេលខាងមុខឆាប់ៗ ដោយបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ រយៈពេល ៥ឆ្នាំ(២០១២-២០១៦) ជាលើកទី២ សម្រាប់អនុវត្តការងារសវនកម្មសាធារណៈឲ្យបានសមស្របតាមស្តង់ដារសវនកម្មសាធារណៈ។

ជាថ្មីម្តងទៀត យើងសង្ឃឹមថា នាពេលអនាគត ឆាប់ៗខាងមុខ អាជ្ញាធរសវនកម្មជាតិនឹងទទួលបានលទ្ធផលល្អប្រសើរក្នុងការអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ រយៈពេល ៥ឆ្នាំ (២០១២-២០១៦) ក្រោមកិច្ចខិតខំប្រឹងប្រែងពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដោយមានការសហការពីគ្រប់មជ្ឈដ្ឋាន ដើម្បីឲ្យវិស័យសវនកម្មសាធារណៈទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ ជាតិមាតុភូមិរបស់យើង។